

# ជីវប្រវត្តិ

## ព្រះអាចារ្យ ហែម-ចៀវ

បោះពុម្ពផ្សាយដោយ
គណៈកម្មការអន្តរក្រសួង

ព.ស. ២៥១៦ + គ.ស. ១៩៧២

922.9593
ជីវ



www.elibraryofcambodia.org

# ជីវប្រវត្តិ
# ព្រះអាចារ្យ ហែម-ចៀវ

✧ ✧

បោះពុម្ពផ្សាយដោយគណៈកម្មការអន្តរក្រសួង
ទទួលបន្ទុករៀបចំពិធីបុណ្យរំលាយអដ្ឋិធាតុ ព្រះអាចារ្យ **ហែម-ចៀវ**
នៅថ្ងៃទី ២០.២១ ខែ កក្កដា ១៩៧២

3



www.elibraryofcambodia.org



**ព្រះអាចារ្យ ហែម-ចៀវ**

កើតឆ្នាំ ១៨៩៨ អនិច្ចធម្ម ឆ្នាំ ១៩៤៣

រដ្ឋាភិបាល ក្រោមអធិបតីភាពនៃលោកសេនាប្រមុខ **លន់-នល់**

ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ សម្រេចនាសម័យប្រជុំកាលពីថ្ងៃទី ២២ មីនា ១៩៧២

ទទួលស្គាល់នូវអំពើល្អទាំងឡាយដែលព្រះអាចារ្យ **ហែម-ចៀវ**

បានធ្វើជូនប្រជាជាតិខ្មែរ ។



www.elibraryofcambodia.org

# សេចក្តីផ្តើម

ហេតុដែលនាំឱ្យកើតបានជាកូនសៀវភៅ ជីវប្រវត្តិអាចារ្យ **ហែម-ចៀវ** ឡើងដោយសាររដ្ឋាភិបាល លោកសេនា ប្រមុខ **លន់-នល់** បានសម្រេចចាត់ឱ្យនាំអដ្ឋិធាតុលោកអាចារ្យ **ហែម-ចៀវ** មកធ្វើបុណ្យជានឡារិក សមតាមកិត្តិយស ដែលជាតិត្រូវតម្កល់តម្កើងលោកជារដ្ឋបុរស។ ក្រសួងធម្មការត្រូវទទួលភារៈរៀបចំកម្មវិធីបុណ្យ និងចាត់ចែងកិច្ចការសព្វសារពើ ធ្វើឱ្យពិធីនេះបានសម្រេច និងបានអធិកអធម សក្តិសមនឹងកត្តិគុណនៃព្រះសពនេះ។

ដូច្នេះ គណៈកម្មការមួយក៏បានបង្កើតឡើងក្នុងផ្ទៃនៃក្រសួង ដើម្បីចាំប្រតិបត្តិឱ្យបានសម្រេចកិច្ចការទាំងពួង។ ក្នុងបណ្តា កិច្ចការទាំងនេះ គណៈកម្មការក៏យល់ថា ត្រូវបោះពុម្ពផ្សាយនូវជីវប្រវត្តិនៃរដ្ឋបុរសរូបនេះឱ្យបានសុសសាយ សម្រាប់ឱ្យមហាជន បានដឹងបានស្គាល់ច្បាស់គ្រប់គ្នាផង ត្បិតសកម្មភាពរបស់លោកផុតរលត់ទៅ ច្រើនឆ្នាំមកហើយ។ ដើម្បីបានសម្រេចបំណងនេះ គណៈកម្មការក៏បានជូនមុខងារទៅលោក **គុយ-ឡូត** ឱ្យទទួលភារៈស្រាវជ្រាវ ហើយរៀបរៀងជាអត្ថបទឡើងក្នុងពេល យ៉ាងឆាប់ ឱ្យទាន់ពិធីបុណ្យ។ លោក **គុយ-ឡូត** ក៏បំពេញមុខការនេះបានទាន់ពេល នាំយកអត្ថបទមកប្រគល់ឱ្យគណៈ កម្មការ ហើយគណៈកម្មការក៏ប្រជុំគ្នាពិនិត្យ ថែមថយសម្រួលអត្ថបទនេះភ្លាម សម្រេចយកជាការ ហើយបោះពុម្ពផ្សាយ ជាសាធារណៈក្នុងវេលានេះ។

ភ្នំពេញ ថ្ងៃទី២៦ ឧសភា ១៩៧២
ប្រធានគណៈកម្មការ,
លោក **ម៉ាំខ-ម៉ូរី**
អនុរដ្ឋលេខាធិការ ក្រសួងធម្មការ



www.elibraryofcambodia.org

# អារម្ភកថារបស់អ្នកនិពន្ធ

តាំងពីក្មេងមក ខ្ញុំបាទតែឮចាស់ៗមានលោកឪពុកខ្ញុំបាទជាដើម ដំណាលនាមលោកអាចារ្យ **ហែម-ចៀវ** ជារឿយៗ ថាលោកមានរឿងត្រូវបារាំងចាប់ផ្សឹក រួចយកទៅដាក់គុកនៅកោះ**ត្រឡាច** លុះគ្រាតែសុគតនៅទីនោះទៅ។ រឿងនេះ ធ្វើឱ្យខ្ញុំបាទចង់ដឹងរឿងរ៉ាវពិតរបស់លោកខ្លាំងណាស់ ទើបសម័យក្រោយៗមក ខ្ញុំបាទតែងព្យាយាមសាកសួរព្រះសង្ឃ និង គ្រហស្ថចាស់ខ្លះៗដែលបានដឹងទាន់រឿងនេះផង មានព្រះបរមសពសម្តេចព្រះសង្ឃរាជ **ជួន-ណាត** ដែលត្រូវជាគ្រូរបស់ លោកអាចារ្យ **ហែម-ចៀវ** ជាដើម។ ក្រៅពីនេះក៏នៅមានព្រះសង្ឃ និង គ្រហស្ថចាស់ៗខ្លះទៀត ដែលបានស្គាល់ព្រះអាចារ្យ **ហែម-ចៀវ** យ៉ាងច្បាស់លាស់ ព្រមទាំងបានចូលរួមសកម្មភាពជាមួយនឹងលោកអាចារ្យនេះផង បានមានពុទ្ធដីកា និងនិយាយ យ៉ាងពិស្តារក្បោះក្បាយឱ្យខ្ញុំស្តាប់ ព្រមទាំងជួយរកឯកសារឱ្យខ្ញុំបាទទៀតផង គឺព្រះពោធិវង្ស **សូ-ហាយ**, ព្រះអាចារ្យ **ម៉ែន-សុខ** ព្រះភិក្ខុ **ប៉ាង-ខាត់** លោក **ប៊ុណ្ណចន្ទ-ម៉ុល**, លោក **ជុំ-មួង**, លោក**ញ៉ូង-សឿង**...។

ខ្ញុំបាទបានរក្សាកំណត់ ដែលបានកត់បន្តិចម្តងៗ តាមពាក្យព្រះសង្ឃ និងអស់លោកជំនាន់នោះពិពណ៌នាទុករហូតមក ដោយពុំទាន់បានរៀបរៀងដើម្បីបោះពុម្ពអ្វីទេ។

តែ, លុះមកដល់ថ្ងៃទី១៨ ខែមេសា ១៩៧២ ក្នុងកិច្ចប្រជុំពិភាក្សារឿងទៅយកព្រះអដ្ឋិធាតុ ព្រះអាចារ្យ **ហែម-ចៀវ** អំពីកោះត្រឡាចនោះ ក្រសួងធម្មការ ដែលមានលោក **ម៉ាំង-មូរី** អនុរដ្ឋលេខាធិការក្រសួងធម្មការជាប្រធាន តម្រូវឱ្យខ្ញុំបាទ ស្រាវជ្រាវរឿងលោកគ្រូអាចារ្យ **ហែម-ចៀវ** នេះឱ្យបានជាក់លាក់, ខ្ញុំបាទនឹកឃើញដល់ឯកសារដែលខ្ញុំបានសន្សំទាំងប៉ុន្មាន, ខ្ញុំបាទក៏មានចិត្តសោមនស្ស ចាប់រៀបរៀងប្រវត្តិរបស់លោកគ្រូអាចារ្យនេះឡើង។

លុះរៀបរៀងរួច ខ្លាចមានការភ្លាំងភ្លាត់ ខ្ញុំបាទក៏ចម្លងជាច្រើនច្បាប់ថ្វាយសម្តេចព្រះសង្ឃរាជ **ហួត- តាត** គណៈមហា និកាយ, ព្រះពោធិវង្ស **សូ-ហាយ**, លោក **ជុំ-មួង**, លោក**ប៊ុណ្ណចន្ទ-ម៉ុល**, លោក **ខ្ទួន-ម៉ឺត** សូមព្រះអង្គ និង អស់លោកទាំងនេះជួយពិនិត្យថែម ដើម្បីឱ្យបានត្រឹមត្រូវ។ រួចហើយខ្ញុំបាទប្រមូលកំណែរបស់ព្រះអង្គ និង អស់លោកទាំងនោះ មកបញ្ចូលតម្រឹមយកជាការបាន។

ក្នុងចិរវេលា ដែលខ្ញុំបាទកំពុងរៀបរៀងរឿងព្រះអាចារ្យ **ហែម-ចៀវ**, ក្រុងភ្នំពេញ តែងបានទទួលរងគ្រាប់ រ៉ុក្កែតជា រឿយៗ ហើយក្រុង និងទីប្រជុំច្រើនកន្លែងក្នុងសាធារណរដ្ឋខ្មែរ កំពុងរងគ្រាប់បែកគ្រាប់កាំភ្លើងតូចធំ... គឺថា ស្រុកខ្មែរកំពុងរង វិនាសកម្មខ្ទេចខ្ទាំសម្បើមណាស់។



www.elibraryofcambodia.org

ខ្ញុំសូមបន់ស្រន់ សូមឲ្យសង្គ្រាមនៅទីនេះឆាប់រលត់ស្ងប់ទៅ សូមឲ្យប្រជាពលរដ្ឋខ្មែរ ដែលកាន់ព្រះពុទ្ធសាសនា បានសុខសប្បាយចម្រើនឡើងវិញ !

**ជយោ ព្រះពុទ្ធសាសនា !**

**ជយោ សាធារណរដ្ឋខ្មែរ !**

ភ្នំពេញ ថ្ងៃសៅរ៍ ១ កើត ខែ ជេស្ឋ ឆ្នាំជូត

ចត្វាស័ក ព.ស. ២៥១៦ ត្រូវនឹងថ្ងៃទី ១៣ ឧសភា ១៩៧២

**គុយ-ឡូត**



www.elibraryofcambodia.org

# ប្រវត្តិអាចារ្យ ហែម ចៀវ

**ខណ្ឌទី ១ : កំណើត**

លោកអាចារ្យ **ហែម-ចៀវ** កើតនៅថ្ងៃអង្គារ ខែមាឃ ឆ្នាំច ព.ស. ២៤៤១ គ.ស.១៨៩៨ នៅឃុំ **ទំនប់ធំ** ស្រុក**ពញាឮ** ខេត្ត**កណ្ដាល**។ ឪពុកឈ្មោះ **ហែម** ធ្វើជាមេស្រុក ម្ដាយឈ្មោះ **ទីវ**។ មានបងប្អូន ៤ នាក់គឺឈ្មោះ **ហែម លី**, **ហែម ហួត**, នាង **ហែម សុច** និងនាង **ហែម-សាយ** ឯលោក **ហែម-ចៀវ** ជាកូនទី ២ បន្ទាប់ពី **ហែម លី** ។

**ខណ្ឌទី២ : ជីវភាពកុមារ**

កាលពីនៅក្មេង កុមារ **ហែម-ចៀវ** មានជីវភាពដូចអ្នកស្រុកអ្នកស្រែធម្មតាដែរ។ ធ្លាប់ដើរតាមម្ដាយទៅស្រែ ធ្លាប់ឃ្វាលគោជាមួយក្មេងគង្វាល ធ្លាប់អាស្រ័យទឹកតាមដានជើងគោ ធ្លាប់ចាំចាប ធ្លាប់អាស្រ័យបាយហាលថ្ងៃក្ដៅ នៅកណ្ដាលស្រែ ធ្លាប់ត្រូវភ្លៀងត្រូវខ្យល់ គឺថាមានសម្បុរស្បែកជាកូនកសិករសុទ្ធសាធ។ ហើយដោយឪពុកម្ដាយជាអ្នក កាន់គោរពព្រះពុទ្ធសាសនាមុតមាំនោះ កុមារ **ហែម-ចៀវ** តែងបានចូលវត្តវាំ ស្ដាប់លោកសូត្រធម៌ លោកទេសន៍រាល់ឱកាសបុណ្យជាមួយឪពុកម្ដាយពុំដែលខាន។

លុះវ័យល្មមឱ្យនៅវត្តហើយ មេស្រុក**ហែម** ជាឪពុកក៏បានមកប្រគេនឱ្យនៅនឹងព្រះគ្រូសង្ឃសត្ថា **ជួន-ណាត** វត្តឧណ្ណាលោមក្រុងភ្នំពេញ ដោយព្រះគ្រូអង្គនេះក៏ជាអ្នកធ្លាប់ប្រស្រ័យរាប់រកជិតដិតរបស់មេស្រុក **ហែម** ស្រាប់។

**ខណ្ឌទី៣ : ជីវភាពសិក្សា**

មកនៅនឹងព្រះគ្រូសង្ឃសត្ថា **ជួន-ណាត**, កុមារ **ហែម-ចៀវ** ជាក្មេងយកចិត្តទុកដាក់រៀនសូត្រអក្សរ លំនាំឥតមានធ្វេសដរាបដល់ចេះអានចេះសរសេរ។ ជាកុមារមានបញ្ញាឆ្លៀវឆ្លាស មានឫកពាសមរម្យ ព្រះគ្រូសង្ឃសត្ថា សព្វព្រះទ័យណាស់ និមន្តទៅណា ទៅសូត្រមន្ត ទៅទេសន៍ តែងតែយកកុមារ **ហែម-ចៀវ** ឱ្យស្ពាយថង់យាមទៅ តាមពុំដែលខាន។

ធ្វើតាមទំលាប់ពុទ្ធសាសនិកខ្មែរ ម្ដាយឪពុកបានបំបួសកុមារ **ហែម-ចៀវ** ជាសាមណេរ ហើយឱ្យនៅនឹង ព្រះគ្រូសង្ឃសត្ថាតទៅទៀត។ សាមណេរ **ហែម-ចៀវ** ក៏ផ្ដើមសិក្សាព្រះបរិយត្តិធម៌ឡើង ហើយការសិក្សាក៏បាន ចម្រើនលូតលាស់ជាលំដាប់។



www.elibraryofcambodia.org

ដល់ជន្មាយុ ២០ ឆ្នាំ (គ.ស.១៩១៧) ក៏បានបំពេញឧបសម្បទាជាភិក្ខុនៅនឹងវត្តលង្កា ដោយមានព្រះមហាវិមលធម្ម **ថោង** ជាព្រះឧបជ្ឈាយ៍ មានព្រះគ្រូបវរវិជ្ជា **លី-ឯម** និងព្រះគ្រូសង្ឃសត្ថា **ជួន-ណាត** ជាគ្រូ សូត្រ។

ដោយការខិតខំឥតធ្វេស នៅឆ្នាំ១៩៦១ ព្រះភិក្ខុ**ហែម-ចៀវ** ក៏បានប្រឡងជាប់សញ្ញាបត្រសាលាបាលីជាន់ខ្ពស់ បានលេខ ៦ ។(Diplôme de L´Ecole Supérieure de Pali)

## **ចំណុចទី៤ : ជីវភាពក្នុងមុខងារ**

សម័យនោះ រាជការអាណាព្យាបាល បានបង្កើតឱ្យមានសាលាបឋមសិក្សានៅតាមវត្តនានាក្នុងប្រទេស ហើយ បង្កើតមុនគេគឺនៅនឹងខេត្តកំពត។ កាលណោះចៅហ្វាយខេត្តកំពតគឺបាំងឈ្មោះ **រសេ្សម** ក៏បានពឹងពាក់លោកគ្រូ មេគុណវត្ត **អង្គសួរគី** ហៅវត្ត**អង្គស្នោរ** ស្រុកកំពង់ត្រាច ខេត្តកំពត ឱ្យជួយរកព្រះសង្ឃដែលមានសញ្ញាបត្រចេញពី សាលាបាលីជាន់ខ្ពស់ ឱ្យមកជួយបង្រៀនព្រះសង្ឃឯទៀតដែលនឹងត្រូវប្រមូលជ្រើសរើសពីវត្តឯទៀតៗ ក្នុងខេត្តកំពត ដើម្បីឱ្យសង្ឃទាំងនោះ មានចំណេះវិជ្ជាគរុកោសល្យ ដើម្បីនឹងបង្ហាត់សាលាបឋមសិក្សានៅក្នុងវត្តរបស់ខ្លួន ហើយត្រូវការ ព្រះសង្ឃដែលមានសមត្ថភាពមកពីភ្នំពេញ នោះជួយត្រួតសាលាបឋមសិក្សាក្នុងខេត្តកំពតផង។ ឱ្យនៅរៀនដើម្បីយក ចំណេះវិជ្ជាទៅបង្ហាត់បង្ហាញនៅសាលាបឋមសិក្សា ដែលនឹងបង្កើតឱ្យមាននៅនឹងវត្តរបស់ព្រះសង្ឃទាំងនោះ។ ឯទីវត្ត ប្រជុំសមណនិស្សិតដើម្បីសិក្សាគរុកោសល្យនោះ គឺវត្តក្រាំងដូង ស្រុកបន្ទាយមាសកំពត។ គឺថាគេនិមន្តលោកទៅនោះ ពុំមែនទៅបង្រៀនធម៌អាថ៌អ្វីទេ គឺឱ្យអប់រំសមណនិស្សិត ដើម្បីឱ្យចេះដឹង ទៅបង្រៀននៅសាលាបឋមសិក្សាតទៅទៀត តែប៉ុណ្ណោះ។ គិតទៅ ផ្នែកអប់រំជាតិយើង ត្រូវមានព្រះសង្ឃជាអ្នកដឹកមុខមុនគេជាដរាប។

ចំណែកព្រះមេគណវត្ត **អង្គសួរគី** កាលបើ **រ៉េ ស៊ីដង់** ខេត្តកំពតពឹងពាក់ដូច្នេះ ក៏និមន្តមកភ្នំពេញជួបនឹង ព្រះគ្រូសង្ឃសត្ថា **ជួន ណាត** ដែលធ្លាប់ស្គាល់គ្នា ឱ្យជួយរកព្រះសង្ឃមានសមត្ថភាពតាមរាជការកំណត់នោះ។ ព្រះគ្រូសង្ឃសត្ថា ក៏ហៅព្រះភិក្ខុ **ហែម-ចៀវ** មកប្រាប់ពិគ្រោះការដោយចង់តម្រូវឱ្យភិក្ខុនេះចេញទៅបំពេញផ្នែកនោះ ផង។ ព្រះភិក្ខុ**ហែម-ចៀវ** ក៏បានព្រមព្រៀងនិមន្តទៅ ដោយសេចក្តីស្ម័គ្រ។

តាំងពីបានចេញពីភ្នំពេញមកបំពេញកិច្ចការនៅក្រាំងដូង ព្រះភិក្ខុ **ហែម-ចៀវ** តែងខិតខំយកចិត្តទុកដាក់បំរើរដ្ឋ និងសាសនាខ្លាំងណាស់ ឥតគិតខ្លាចនឿយហត់សោះឡើយ។ លោកបានបង្ហាត់បង្រៀនព្រះសង្ឃដែលមករៀននោះ ដោយព្រះទ័យស្មោះ និងដោយខិតខំបំផុត



www.elibraryofcambodia.org

លោកតែងមានពុទ្ធដីកាថា លោកចង់ឱ្យព្រះសង្ឃទាំងនោះចេះដឹង ដើម្បីយក ចំណេះនោះទៅបង្រៀនកូនចៅខ្មែរតទៅទៀតឱ្យចេះដឹងព្រមគ្នាផង។ ក្រៅពីការបង្ហាត់គរុវិជ្ជា ភិក្ខុ**ហែម-ចៀវ** ត្រូវបាន ឧបាសក ឧបាសិកាជាច្រើនវត្តនិមន្តទៅសម្តែងធម៌ទេសនា ពន្យល់ពីបុណ្យបាប ពីផ្លូវលោកនិងផ្លូវធម៌ ដែលមានគេ ចុះចូលពេញចិត្តនឹងលោកជាច្រើន។ ដោយចិត្តមេត្តា និងសន្តោសនេះ មានព្រះសង្ឃនិងពុទ្ធបរិស័ទចូលចិត្តលោកណាស់។

នៅខែមីនា ១៩៣១ សាលាបាលីជាន់ខ្ពស់ ត្រូវការជ្រើសរើសសាស្ត្រាចារ្យភាសាបាលីពីររូប។ បេក្ខជនដែលអាច ប្រលងបាន ត្រូវមានជាចាំបាច់មធ្យមសិក្សាបត្រសាលាបាលីជាន់ខ្ពស់។ ព្រះភិក្ខុ**ហែម-ចៀវ** ក៏ ឆ្លៀតមកប្រឡងនឹងគេ ដែរ។ តែគួរឱ្យស្តាយបន្តិច ក្នុងការប្រឡងជ្រើសរើសនោះ លោកប្រឡងជាប់លេខ៣ ដូច្នេះលោកពុំបានជាប់ជា សាស្ត្រាចារ្យដូចបំណងឡើយ ឯអ្នកជាប់លេខ១ និងលេខ២ ដែលត្រូវតែងតាំងជាសាស្ត្រាចារ្យនោះ ក៏ជាមិត្តរបស់លោក ដែរ គឺព្រះភិក្ខុ **អ៊ុច-រស់** និង **ម៉ែន-សុខ** ។ ព្រះភិក្ខុ **ហែម-ចៀវ** ក៏ទៅនៅក្រាំងដូងវិញ។

ប៉ុន្តែកន្លងមកប្រមាណជា ៦ ខែ សាស្ត្រាចារ្យម្នាក់នៅសាលាបាលីជាន់ខ្ពស់ គឺអ្នកឧកញ៉ាព្រះធម្មប្រីជា នាម **អុខ** បានទទួលអនិច្ចកម្មទៅ លោកក្រមការ **ជុំ-ម៉ៅ** ធ្វើការនៅព្រះរាជបណ្ណាល័យ ដែលជាអ្នកចាត់ការក្នុងសាសនសិក្សាធិការ ក៏បានពិគ្រោះនឹងព្រះគ្រូសង្ឃសត្ថា ចង់សុំតាំងព្រះភិក្ខុ **ហែម-ចៀវ** ជាសាស្ត្រាចារ្យ ជួសឡើង ដោយពុំចាំបាច់ប្រឡង ទៀត ព្រោះលោកកាលប្រឡងនោះក៏ជាប់លេខ ៣ ស្រាប់។ ព្រះគ្រូសង្ឃ សត្ថាសុំឱ្យលោក **ជុំ-ម៉ៅ** ពិគ្រោះនឹងអស់ លោកឯទៀតចុះ កុំឱ្យមានពាក្យគេថាលោកជួយតែសិស្សរបស់ឯង។ លោក **ជុំ-ម៉ៅ** ក៏បានពិគ្រោះនឹងអ្នកធំខាងលើ ទៀតជាដើមគឺនាងកញ្ញា**ករាមីឡេស** អ្នកគ្រប់គ្រងព្រះ រាជបណ្ណាល័យ, ព្រះមហាវិមលធម្ម **ថោង** ចាងហ្វាងសាលា បាលីជាន់ខ្ពស់, **រេស៊ីដង់ស៊ុប៉េរីយើរ** ព្រមទាំងសម្តេចចក្រី **ប៉ុណ្ណ** រដ្ឋមន្ត្រីក្រសួងសិក្សាធិការ។ អស់លោកទាំង នោះ បានយល់ព្រមតាមសំណើនេះ។

ថ្ងៃទី២២ ខែកម្ភៈ ១៩៣២ ព្រះភិក្ខុ**ហែម-ចៀវ** បានត្រូវតែងតាំងជាសាស្ត្រាចារ្យភាសាបាលី នៅសាលាបាលី ជាន់ខ្ពស់។

ហើយបន្ថែមលើនាទីសាស្ត្រាចារ្យនេះ លោកត្រូវតែងតាំងជាសមាជិកក្រុមជំនុំព្រះត្រៃបិដកផងទៀត (រាជបញ្ញត្តិ លេខ៣៦ ចុះថ្ងៃទី២៦ មីនា ១៩៣២ ក្នុងជំនាន់ហ្លួងស៊ីសុវត្ថិមុនីវង្ស និង **រេស៊ីដង់ស៊ុប៉េរីយើរ ស៊ីលវ៉េស្ត្រ**) ។



www.elibraryofcambodia.org

កាលបើបានធ្វើជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ហើយ លោកក៏បានមានមិត្តភក្តិជាអ្នកចេះដឹង កាន់តែច្រើន ជាពិសេសបាននៅជិតព្រះសង្ឃកំពូលៗជំនាន់នោះផង ដែលរឹតតែធ្វើឱ្យលោកមានចំណេះដឹង ទូទៅកាន់តែប្រសើរឡើង។ ម្យ៉ាងទៀត ការបង្ហាត់បង្រៀនសិស្ស ក៏អាចឱ្យលោកមានការពិសោធជ្រាលជ្រៅ ថែមទៀត។ សាស្ត្រាចារ្យសម័យនោះ គេហៅខ្លីថា «អាចារ្យ»។ លោកអាចារ្យ **ហែម-ចៀវ** មានគេស្គាល់ដោយច្រើន ដោយសាលោកពូកែបង្រៀនពូកែ ទេសន៍ ប៉ុន្តែសំខាន់បំផុតដែលធ្វើឱ្យលោកមានឈ្មោះល្បីនោះគឺត្រង់លោកជាព្រះសង្ឃស៊ីវិល័យ ភ្លឺស្វាង មានគំនិត ថ្មីៗជាច្រើន ពោលឱ្យចំទៅ គឺថាលោកជឿនលឿន ស្រឡាញ់ឯករាជ្យស្រុកទេស ហ៊ាននិយាយហ៊ានថា ដែលសម័យនោះ គេពុំសូវហ៊ាន។

លោកអាចារ្យ **ហែម-ចៀវ** មានរូបលក្ខណៈ ស្មាធំ ចង្កេះរៀវ ថ្ងាសទូលាយ ថ្គាមថ្លែន សម្លេងក្រាងក្រឌី មូលគ្រលួចៗ ជាអ្នកមានវោហារ បានមាត់បានក គេចូលចិត្តសម្តីលោកណាស់។ លោកមានកិរិយាស្រគត់ ស្រគំ ហើយមានបរិមណ្ឌលសមរម្យមិនរយីករយាក ឫកពាថ្លៃថ្នូរ និងសង្ហា។ លោកជាអ្នកមានអនាម័យ។

**ខណ្ឌទី៥ : និស្ស័យគំនិត**

ក) លោកអាចារ្យ **ហែម-ចៀវ** មានគំនិតជឿនលឿននិយម ចូលចិត្តដឹងស្ថានការណ៍ពិភពលោក។ លោកចូលចិត្តអានសារព័ត៌មាន ទស្សនាវដ្តីជាភាសា **ថៃ** និងកាសែត **បារាំង** មានកាសែត **ឡាទេរីអេ អូពីនីញ៉ុង អាំប៉ាស្យ៉ាល់** និង **ប្រេសដឺសេហ្គុង**។ ឯសារព័ត៌មាន និងទស្សនាវដ្តីជាតិយើងពុំទាន់មានទេ មានតែសារព័ត៌មាន **នគរវត្ត** ដែលចាប់ចេញផ្សាយពីឆ្នាំ១៩៣៦ ដែលដឹកនាំដោយលោក **សឺន-ង៉ុកថាញ់, ប៉ាច-ឈឺន, ស៊ីម-វ៉ា**....ឯទស្សនាវដ្តីគ្មានសោះ។

សម័យនោះ ប្រជាជនពិភព **អារ៉ាប់** និង **អាហ្វ្រិក** ដែលនៅក្រោមអាណានិគម**បារាំង** ចេះមានគំនិត បះបោរទាមទារយកឯករាជ្យហើយ ហើយមេអាណានិគមនិយមនេះតែងតែប្រើកម្លាំងអាវុធបង្ក្រាបប្រទេសទាំងនោះ។ ដំណឹងទាំងនោះនាំឱ្យលោកអាចារ្យ **ហែម-ចៀវ** មានគំនិតកាន់ជើងជួយគិតវាសនាប្រទេសតូចតាចទាំងនោះ រួចផ្ទួរផ្ទងមកនឹងប្រទេសខ្មែរដែលនៅក្រោមអំណាចបារាំងផងដែរ។ លោកតែងនិយាយស្ទាត់កំបាំងថាបារាំងជាអ្នកជិះជាន់គេណាស់។

លោកអាចារ្យ **ហែម-ចៀវ** មានមិត្តបារាំងម្នាក់ឈ្មោះ **ម៉ានីពូ** ដែលចេះតែនិយាយពីរឿងនយោបាយ សកលលោកប្រាប់ហាក់ដូចជារឹតតែបំភ្លឺលោកឱ្យកាន់តែភ្លឺឡើងទៀត។



www.elibraryofcambodia.org

សម័យនោះផងដែរ **បារាំង** និង **អាឡឺម៉ង់** ផ្ដើមច្បាំងគ្នា លោកអាចារ្យ **ហែម-ចៀវ** បានតាមដាន ព្រឹត្តិការណ៍នោះរាល់ៗថ្ងៃ ហើយបើឃើញពត៌មានថាទ័ព **បារាំង** ចាញ់ **អាឡឺម៉ង់** លោករមែងមានពុទ្ធដីកាប្រាប់ សិស្សគណថា **បារាំង**អន់ណាស់ **អាឡឺម៉ង់**ទើបពូកែ !

សម័យនោះប្រទេសយើងនៅក្រោមអំណាចបារាំង មន្ត្រីខ្មែរភាគច្រើនសឹងតែចូលចិត្តបារាំង ផ្គាប់ផ្គុនបារាំងដើម្បី បុណ្យសក្តិ គេមិនត្រូវការនឹងរឿងរំដោះស្រុកទេសអ្វីទេ។ ពំនោលរបស់ព្រះអាចារ្យ**ហែម-ចៀវ** រមែងជ្រួតជ្រាបដល់ ត្រចៀកអស់លោកទាំងនោះ មិនដែលធ្វើឱ្យអស់លោកទាំងនោះមិនសប្បាយចិត្ត។ គេកូចក្នុងចិត្តថាលោកអាចារ្យ **ហែម-ចៀវ** នេះមានគំនិតប្រឆាំងនឹងបារាំងហើយ។

លោកគ្រូអាចារ្យ **ប៉ែន-សុខ** ដែលជាមិត្តភក្តិ ដឹងថាមានគេមិនសប្បាយចិត្តនឹងព្រះអាចារ្យ **ហែម-ចៀវ** ក៏ប្រាប់រំលឹកព្រះអាចារ្យនេះថា :

«សូមឱ្យលោកប្អូន **ចៀវ** ឯងប្រយ័ត្នមាត់បន្តិចទៅ ពីព្រោះមានគេសំគាល់ថា យើងប្រឆាំងនឹងបារាំង ប្រយ័ត្នគិញបារាំងគេយកការណ៍បាន គេនឹងចាប់ទៅធ្វើទោស!

តែលោកអាចារ្យ **ហែម-ចៀវ** ឆ្លើយតបវិញថា :

«លោកបង **សុខ** ឯង បើមិនហ៊ាននិយាយ នៅឱ្យស្ងៀមទៅ! បើមិនជួយចូកជួយចែវកុំយកជើងរាទឹក! នៅឱ្យស្ងៀម! ចាំផ្អិនស៊ីមស៊ីទៅ! សម័យនេះត្រូវតែហ៊ាននិយាយខ្លះ ដាស់គ្នាឱ្យយល់រឿងពិភពលោក ពិភពលោកគេភ្ញាក់ផ្អើលខ្លះ ហើយ យើងត្រូវបើកភ្នែកមើលគេខ្លះផង!

លោកអាចារ្យ **សុខ** ក៏នៅស្ងៀមខ្លាចព្រះអាចារ្យ **ហែម-ចៀវ** បន្ទោស។

លោកអាចារ្យ **ហែម-ចៀវ** មានសិស្សជំនិតមួយរូប គឺលោក **ខ្វួន-ខួច** ។ លោក**ខ្វួន-ខួច** មាននិស្ស័យ ដូចលោកដែរ។

ខ) ដោយនិស្ស័យគំនិតជាអ្នកបដិវត្តន៍ ដែលសម័យនោះគេមិនដឹងនឹងឱ្យឈ្មោះហៅថាដូចម្តេចផង លោកអាចារ្យ **ហែម-ចៀវ** តែងតែចង់ឃើញស្រុកទេសចេញផុតពីចំណុះគេ ចង់ឃើញការតស៊ូរបស់ប្រជាជនខ្មែរដើម្បីឯករាជ្យ។ ដូច្នេះ ទេសនាក្នុងទីណាក៏ដោយ ពេលអ្វីក៏ដោយ ច្រើនតែផ្តៀងទៅលើការរំលឹកដាស់តឿនពុទ្ធបរិស័ទឱ្យយល់រឿង ជាតិនោះជាដរាប។ ធម្មទេសនារបស់លោក មានច្រើនតែរឿង វិរិយ ព្យាយាម កុំឱ្យខ្ជិលច្រអូស។ លោកថាការខ្ជិលច្រអូស បណ្តែតបណ្តោយ ប្រចាំគេប្រចាំឯងនោះ គឺជាទោស នាំឱ្យខ្លួនធ្លាក់ទៅក្នុងទាសភាពដោយត្រង់តែម្តង។ លោកចូលចិត្ត យកពាក្យ «ទាសភាព» នេះមកវែកញែកណាស់ ហើយផ្គូរផ្គងប្រៀបធៀបជារបៀបដាស់តឿនសម្រាប់ស្រុកទេសផង លោកមានពុទ្ធដីការឿយៗថា យើងរាល់



www.elibraryofcambodia.org

គ្នានៅក្នុងវដ្ដសង្សារនេះ សឹងស្ថិតនៅក្នុងអានុភាពរបស់កិលេសគ្រប់គ្នា យើងជា «ទាសករ» របស់កិលេសគ្រប់គ្នា។ ទាសភាពនេះជាទម្ងន់សង្កត់ជីវិតមួយជាន់ទៅហើយ ប៉ុន្តែធ្វើដូចម្ដេច បើយើងនៅ ត្រាំក្នុងអន្លង់វដ្ដសង្សារដូច្នេះទៅហើយ នឹងគេចទៅឯណារួច? យើងទ្រាំចុះ! ប៉ុន្តែបើយើងនេះឯង សុខចិត្តប្រគល់ខ្លួនជា «ទាសករ» របស់មនុស្សដូចគ្នាទៀតនោះ ការនេះគួរឱ្យស្ដាយពេកណាស់ យើងដូចជាសត្វធាតុតែម្ដង! យើងមិនគួរទទួល ទម្ងន់ «ទាសភាព» នេះមកទូលរែកទៀតសោះ!

លោកអាចារ្យ **ហែម-ចៀវ** បានរំលឹកសិស្សគណថា កើតមកជាមនុស្សត្រូវមានការព្យាយាម តស៊ូ កុំអស់ សង្ឃឹមឱ្យសោះ។

អំពីរឿងព្យាយាម «វិរិយៈ» លោកឧស្សាហ៍នាំព្រះជនកជាតកមកដំណាលណាស់ ស្ទើរគ្រប់រឿងដែលត្រូវទេសនា។ ដើម្បីពន្យល់អ្នកស្ដាប់ឱ្យកើតគំនិតព្យាយាមឡើង លោកថា : ព្រះជនកពោធិសត្វ លោកពុំលះបង់វិរិយភាពឡើយ ស្ទើរលិចសំពៅវង្វេងកោះត្រើយ ឃើញមុខជាស្លាប់កណ្ដាលសមុទ្រនោះដូចម្ដេច ក៏លោកនៅតាំងស្មារតីត្រដរហែលតទៀត ថែមទាំងឆ្លៀតខ្ពុរមាត់ សំអាតធ្មេញ ទន្និញធម៌ អធិដ្ឋាន ពេលព្រះចន្ទពេញបូណ៌មី ដែលលោកមើលពីក្នុងសមុទ្រទៅ. . . គឺលោកមានវិរិភាពមាំណាស់ ពុំបណ្ដោយឱ្យការអស់សង្ឃឹមមកទាញយកសង្ខារលោក ឡើយ។ នោះរឿងមហាជនក នៅក្នុងលំហសមុទ្រម្ដេចក៏គង់លោកខំទាល់តែបានសម្រេច ចុះយើងរាល់គ្នានៅលើគោកត្រលាំង ម្ដេចក៏ខ្ជិល ម្ដេចក៏ដាក់ធុរៈ ចំពោះកិច្ចការ? ម្ដេចក៏ចាំវាសនាមកជីកមុខ? រួចពីពោលដូច្នេះ ព្រះអាចារ្យ **ហែម-ចៀវ** ក៏ពោលបញ្ជៀងៗមករឿង ស្រុកទេស ដែលរាល់គ្នាត្រូវព្យាយាមរចនាឱ្យប្រសើរថ្លៃថ្លាឡើង។

គ) ប្រការមួយទៀត លោកចូលចិត្តទេសនារំលឹកដាស់តឿនប្រជាជនខ្មែរឱ្យមានគំនិតភ្លឺថ្លា លះបង់ទម្លាប់អាក្រក់នៅ ក្នុងសង្គមផង។

សម័យនោះ ខ្មែរយើងនៅមានទម្លាប់ម្យ៉ាងក្នុងរឿងរៀបចំកូនឱ្យមានគូស្រករ គឺម្ដាយឪពុកខាងស្រី ចូលចិត្តឱ្យកូន ប្រសាបំរុងការមកនៅបម្រើខ្លួន ជូនកាលបង្គាប់ឱ្យខាងប្រុសធ្វើផ្ទះគ្បៀងគ្រឿងស្រឡៅបីបួនខ្នងឱ្យខ្លួន។ ការបង្គាប់ដូច្នោះ លោកយល់ថា ជាអយុត្តិធម៌ពេកណាស់ ហើយខុសនឹងសង្គហធម៌ផង។ ព្រោះម្ដាយឪពុកត្រូវមានសង្គហធម៌ចំពោះកូនមិន ថាប្រុសថាស្រីទេ គឺសង្គ្រោះស្រឡាញ់ស្មើ បើយើងគាបសង្កត់តែ ទៅលើកូនប្រុសដូច្នេះ ហាក់យើងមិនពេញចិត្តកូន ប្រុសសោះ កូនប្រុសនោះពុំមែនមានតែខាងគេទេ យើងក៏មានដែរ ហើយបើយើងមិនព្រមនាំគ្នាជម្រុះទម្លាប់នេះចេញទេ កូនប្រុសយើងក៏ត្រូវធ្ងន់កដែរពេលដែលទៅស្ដីដណ្ដឹងកូនស្រី



www.elibraryofcambodia.org

គេនោះ។ ម្យ៉ាងទៀត ការគាបសង្កត់ខ្លាំងពេក គឺបង្ហាប់ខ្លាំង ពេករហូតដល់ខាងប្រុសគ្នា ធ្លាក់ក្រដុនដាបនោះ វាមិនមែនវេទនាតែខាងប្រុសនោះទេ ខាងកូនស្រីយើងឯងនេះ ក៏ត្រូវ វេទនាទៅផងដែរ។ ហេតុនេះបើយើងបន្ធូរបន្ថយខ្លះ ជួយសម្រាលខ្លះទៅនោះ ក៏ដូចជាជួយខ្លួនយើងទៅវិញទេ។ កូនប្រសាយើងបានធូរ កូនស្រីយើងក៏បានស្រួល យើងជាម៉ែឪក៏ស្រណុកចិត្ត គ្រួសារទាំងមូលក៏មានសុភមង្គល។

ឃ) លោកអាចារ្យ **ហែម-ចៀវ** ចូលចិត្តអប់រំឱ្យម្ដាយឪពុកបញ្ជូនកូនទៅសាលារៀន។

ឆ្លៀតឱកាសជារឿយៗ លោកបានរំលឹកដាសតឿនឱ្យពុទ្ធបរិស័ទបញ្ជូនកូនចៅទៅរៀននៅសាលា ដែលរាជការបាន បង្កើតតាមវត្តខ្លះ ហើយថាឱ្យនាំកូនចៅឱ្យទៅរៀននៅក្រុងផងទៅ ដោយសុំផ្ដាំផ្ញើទុកនឹងលោកសង្ឃ។ លោកតែងថា ការចេះដឹង ជាពន្លឺធំណាស់ កាលណាយើងល្ងង់ បីដូចជាភ្នែកងងឹតចេះតែដើរទៅពានគ្រោកពានគ្រាំង។ សម័យនោះ ប្រជាជនខ្មែរយើងពុំសូវឱ្យកូនចៅទៅរៀននៅសាលាទេ យល់ថាសាលានោះជាសាលាបារាំង រៀនទៅពូកបារាំងកេណ្ឌ យកទៅធ្វើទាហាន។ លោកគ្រូអាចារ្យ **ហែម-ចៀវ** តែងតែជួយពន្យល់បំបាត់កម្លាចនោះចេញជារឿយៗ។

ង) ក្រៅពីនេះ លោកអាចារ្យ **ហែម-ចៀវ** តែងតែគិតដល់សុខភាពនៃអ្នកភូមិផង។

នៅតាមភូមិស្រុកដែលលោកបាននិមន្តទៅដល់ បើឃើញក្មេងក្មាងឯណាមិនស្អាតប្រឡាក់ប្រឡូស លោកតែងនាំទៅ និទានជាឧទាហរណ៍ឱ្យអ្នកឯទៀតសំអាតកូនចៅ ដោយរំលឹកថា តែមានការកខ្វក់ ការប្រឡាក់ប្រឡូស នឹងនាំឱ្យមានរោគ មានជំងឺ ហើយបើមានជំងឺឆ្លងផងទៀតនឹងឆ្លងស្លាប់អស់ទាំងភូមិមិនខាន។ លោកថា ខ្មែរយើងស្លាប់ដោយជំងឺសឆ្លងនេះ ច្រើនលើកមកហើយ តាំងពីសម័យឧដុង្គមក ស្លាប់ដោយរោគអុត អាសន្នរោគ អហិវាតរោគ ស្ទើរលើងពីស្រុក។ លោកថាខ្មែរយើងមានគ្នាតិចផង បើស្លាប់ដោយរោគរាតត្បាតស្ទើរពាយដូច្នេះទៀតមុខគួរឱ្យស្ដាយពន់ពេកណាស់ លោកសុំឱ្យពុទ្ធបរិស័ទសំអាតកូនចៅ និងរូបកាយ ចៀសវាងជំងឺផង។

ច) ទស្សនៈចំពោះសង្គម

ជាមួយនឹងជីវភាពសង្គមសម័យនោះ លោកអាចារ្យ **ហែម-ចៀវ** តែងតែទាស់ព្រះទ័យយ៉ាងខ្លាំង ព្រោះមិនឃើញមានជនជាតិខ្មែរស្រវាស្រទេញរៀនវិជ្ជាបច្ចេកទេសអ្វីសោះ។ សម័យនោះពួកយន្តការី ធ្វើឡាន ធ្វើម៉ាស៊ីនអ្វីៗសុទ្ធតែ ជនជាតិយួន សូម្បីអ្នកតខ្សែភ្លើងក៏ជាជនជាតិយួនដែរ ខ្មែរគ្មានម្នាក់សោះ។ លោកចង់ឱ្យខ្មែរយើងចេះដឹងវិជ្ជាផ្នែកនេះណាស់ ព្រោះដូចជា



www.elibraryofcambodia.org

យ៉ាប់ពេក ខ្មែរម្ចាស់ស្រុកហើយ ទៅពឹងគេឱ្យធ្វើការ ជួស សព្វបើរឿងជួសជុលឡាន តខ្សែភ្លើង អ្វីៗដូច្នេះ។

ដោយគំនិតនេះ លោកអាចារ្យ **ហែម-ចៀវ** ក៏ចាត់ឱ្យកូនសិស្សលោកជាច្រើននាក់ទៅរៀននៅសាលាដែក និងរៀនរឿងខ្មៅខ្វងម៉ាស៊ីនភ្លើងគ្រឿងភ្លើងនេះ មានឈ្មោះ **ម៉ៅ** ជាដើម ដែលក្រោយមកចេះដឹងគ្រាន់បើគ្រឿងម៉ាស៊ីន រថយន្តផ្សេងៗ។

ឈ្មោះ **ម៉ៅ** នេះ តែងខ្ចីឡានគេបើកជូនលោកអាចារ្យ ពេលដែលលោកត្រូវគេនិមន្តទៅទេសន៍ខេត្តឆ្ងាយៗ។

សូមបញ្ជាក់ថា សម័យនោះ ឡានឈ្នួលតិចណាស់ ពិបាករង់ចាំជិះណាស់ ហើយទៅមកយូរពេកផង។ បើគេនិមន្ត ទាល់តែទៅមុនពេលកំណត់បុណ្យទើបបាន មកវិញក៏ដូចគ្នាដែរ គឺរអាក់រអួលណាស់ មិនដូចចិត្តទេ។ ដំណើរនោះនាំឱ្យ ខកច្រើន ហើយខូចពេលដែលត្រូវបង្ហាត់បង្រៀនសិស្សសាលាបាលីផង។ លោកមាន សិស្សចាំជួយរករថយន្តដូច្នេះជាការ ស្រួល ចង់និមន្តចេញទៅថ្មើរម៉ោនក៏បាន មកវិញថ្មើរម៉ោនក៏បាន មិនខាត ពេលធ្វើការនៅភ្នំពេញឯណេះ។

ព្រះអាចារ្យ **ហែម-ចៀវ** ត្រូវគេនិមន្តខ្វាត់ខ្វែងសម្បើមណាស់ និមន្តទេសន៍ និមន្តឱ្យទៅជួយរៀបចំបុណ្យ ស៊ឹងតែគ្មានលស់អាទិត្យ។ លោកជាអ្នកពូកែចាត់ចែងរៀបចំបុណ្យ បុណ្យអ្វីក៏ដោយ បុណ្យខ្មោច បុណ្យផ្កា បុណ្យកឋិន បុណ្យជាទម្លាប់របស់ខ្មែរ។ កាលបុណ្យសពញោមព្រះអាចារ្យ **ម៉ែន សុខ** ជាមិត្តនោះ ក៏មានលោកអាចារ្យ **ហែម-ចៀវ** ជាអ្នកជួយដែរ។

សម័យនោះគេត្រូវការលោកសម្បើមណាស់។ ឈ្មោះលោកក៏កាន់តែលេចឮខ្លាំងឡើងនៅក្នុងប្រទេស។ សម័យនោះ គេល្បីថា សិស្សរបស់ព្រះគ្រូសង្ឃសត្ថា **ជួន-ណាត** ពូកែទេសន៍ និងចេះដឹងសម្បើមណាស់ ។ លុះព្រះគ្រូសង្ឃសត្ថា ឡើងងារជាព្រះពុទ្ធឃោសាចារ្យ ព្រះអាចារ្យ **ហែម-ចៀវ** ក៏បានងារជាព្រះបាឡាត់ឃោសនាគរបស់ព្រះពុទ្ធ ឃោសាចារ្យតមក។ កាលណោះលោកគង់នៅជាមួយនឹងព្រះពុទ្ធឃោសាចារ្យកុដិជាមួយគ្នា គឺកុដិមួយស្ថិតនៅខាងក្រោយមហាកុដិសម្តេចព្រះសង្ឃរាជ នាវត្តឧណ្ណាលោមសព្វថ្ងៃនេះ។

ឆ) លោកគ្រូអាចារ្យ **ហែម-ចៀវ** ជាអ្នកដឹងគុណមាតាបិតាខ្លាំណាស់ លោកឧបត្ថម្ភមាតាបិតាដោយ សេចក្តីគោរព។ ម្យ៉ាងវិញទៀត ចំពោះព្រះពុទ្ធឃោសាចារ្យ **ជួន-ណាត** ជាគ្រូនោះ ក៏លោកគ្រូអាចារ្យ **ហែម-ចៀវ** គោរពប្រណិប័តន៍ណាស់ លោកបម្រើគ្រូ តាមតែគ្រូត្រូវការ។

ក្នុងសម័យមួយនោះ ឆ្នាំ១៩៣៩ មានលោកគ្រូចៅអធិការមួយអង្គនាម **ឱក-ឱម** ចង់បានសៀវភៅធម៌មួយមុខ ក្នុងការដែលលោករៀបចំធ្វើបុណ្យមួយ លោកក៏បានអារាធនាព្រះពុទ្ធ



www.elibraryofcambodia.org

ឃោសាចារ្យរៀបរៀងធម៌នោះ ដើម្បីលោកនឹងយក ទៅបោះពុម្ពចែកជាធម្មទានក្នុងពេលបុណ្យ។ ដោយមានការងារមមាញឹកពេក ក្នុង ឋានៈលោកជាចាហ្វាងវងសាលាបាលី ជាន់ខ្ពស់ ពុំមានពេលនឹងរៀបរៀងបាន ព្រះពុទ្ធឃោសាចារ្យ**ជួន-ណាត**ក៏ប្រគល់ភារៈឱ្យព្រះបាឡាត់ឃោសនាគ **ហែម-ចៀវ** រៀបរៀងធម៌នោះ។ ព្រះអាចារ្យ **ហែម-ចៀវ** ក៏ទទួលភារៈធ្វើដោយសេចក្តីគោរព។ ពេលនោះលោក ឆ្លៀតសម្បើមណាស់ ព្រោះលោកក៏រវល់ណាស់ដែរ។ អត្ថបទធម៌ដែលលោករៀបរៀងនោះ មានចំណងជើងថា : «ទានកថា» ដែលនិយាយដោយពិស្តារ អំពីការឱ្យទាន - ឈ្មោះទាន - របៀបឱ្យទាន - និងអានិសង្សរបស់ទាន។ អត្ថបទធម៌នោះត្រូវបានពុទ្ធសាសនបណ្ឌិត្យបោះពុម្ពផ្សាយតាំងពីឆ្នាំ១៩៣៩ នោះដល់គ្រានេះ។

ជ) ព្រះអាចារ្យ **ហែម-ចៀវ** ចូលចិត្តធ្វើទាន :

ព្រះអាចារ្យ **ហែម-ចៀវ** ពុំមែនជាអ្នកសន្សំមានបានអ្វីឡើយ ប្រាក់កាសដែលលោកបានមកពីទេសនា ឬបានមកពីគេប្រគេនផ្សេងៗ លោករមែងចែករំលែកឱ្យសិស្សគណនិងអ្នកក្រលំបាកដែលលោកបានប្រទះ។

ក្នុងធម្មទេសនារបស់លោក លោករមែងរំលឹកដាស់តឿនថៅកែ គហបតី អ្នកមាន ឱ្យមានសទ្ធាជ្រះថ្លាក្នុងការ ឱ្យទាន។ ឱ្យអ្នកមាន មានចិត្តសន្តោស មេត្តាចំពោះអ្នកក្រ រួចលោកឆ្លៀតពន្យល់មនុស្សឱ្យមានសមភាព ភាតរភាព ឱ្យមានការរាប់រកគ្នាទៅវិញទៅមក កុំប្រកាន់ពូជពង្សខ្ពស់ទាប មានក្រ . . . លោកយល់ ថាមនុស្សកើតមកមានវេទនារម្មណ៍ ដូចៗគ្នា មានសម្រេកឃ្លានដូចគ្នា មានចំណង់ចង់បានសុខសប្បាយដូចគ្នា . . . ដូច្នេះត្រូវតែមនុស្សផ្តល់សង្គ្រោះចំពោះគ្នា នឹងគ្នាផង។

ជាការពិតដែលបង្ហាញនូវគំនិតរបស់លោកនេះ នៅក្នុងសៀវភៅ «ទានកថា» របស់លោក លោកបានសរសេរ មួយអន្លើថា : ពួកសត្វទាំងអស់សុទ្ធតែមានសេចក្តីសុខទុក្ខជាប់ទាក់ទងដោយរាងកាយ ឬថាមានរាងកាយជាទីអាស្រ័យ នៅនៃសេចក្តីទុក្ខ ដូចគេហដ្ឋានជាទីអាស្រ័យនៅនៃមនុស្ស។ ជីវិតដែលតាំងនៅបាន ក៏ព្រោះអាស្រ័យរាងកាយ ការគ្រប់គ្រងចិញ្ចឹមរាងកាយដោយអាហារផ្សេងៗ ក៏ឈ្មោះថាគ្រប់គ្រងជីវិត។ ការរក្សាជីវិតរបស់មនុស្សទាំងអស់ ជាភារៈយ៉ាងធ្ងន់បំផុត សាច់ឈាម ស្បែកសរសៃ ពណ៌សម្បុរ ដែលចម្រើនស្រស់បស់ឡើងបាន ក៏ព្រោះអាស្រ័យអាហារ កាលបើប្រាសចាកអាហារហើយ សន្តតិរូប គឺរូបដែលចម្រើនជាប់តទៅ ក៏ឈប់ចម្រើន រាងកាយទាំងមូលក៏ស្វិតស្រពោន ថយចុះទៅ ទាំងជីវិតសោតក៏តាំងនៅបានដោយក្រ។ អាហារជារបស់សំខាន់សម្រាប់បម្រុងជីវិតឱ្យប្រព្រឹត្តទៅ សមដូច បាលីថា : «សព្វេ សត្តា អាហារ



www.elibraryofcambodia.org

ដ្ឋិតិកា» «ពួកសត្វរាល់រូបមានជីវិតតាំងនៅបានព្រោះអាហារ»។ វត្ថុដទៃក្រៅអំពីអាហារនោះទៀត ជនជាតិមនុស្សត្រូវ មានលំនៅសម្រាប់ជាទីជ្រកកោន សំពត់សម្រាប់ស្លៀកដណ្តប់ ថ្នាំសម្រាប់កែរោគក្នុងគ្រា ដែលត្រូវការ វត្ថុអម្បាលនេះ សុទ្ធតែជារបស់សម្រាប់ឧបត្ថម្ភទប់ទល់ជីវិតដោយពិត បើប្រាស់ចាករបស់ណាមួយ ជីវិត រមែងតាំងនៅបានដោយលំបាក។ ជនជាតិមនុស្ស លុះតែមានចំណេះវិជ្ជា ឬកម្លាំងកាយ កម្លាំងប្រាជ្ញាបរិបូរណ៍ ទើបអាច ស្វែងរកអាហារបានបរិភោគ រកទីអាស្រ័យនៅ និងគ្រឿងប្រើប្រាស់សម្រាប់ជួយជីវិតបានគ្រប់គ្រាន់ល្អ។ ចំណែកមនុស្ស ដែលគ្មានចំណេះវិជ្ជា ខ្សោយកម្លាំង ឬ ឥតគុណសម្បត្តិណាមួយក៏មិនអាច រក្សាជីវិតរាងកាយ ឱ្យរស់នៅតាមទំនើង ខ្លួនឯងបានឡើយ មនុស្សបែបនេះ ត្រូវអាស្រ័យពឹងផ្អែកនឹងអ្នកដទៃឱ្យគេជួយចិញ្ចឹមជីវិតរបស់ខ្លួនជាដរាប គឺឱ្យជួយប្រាប់ ឧបាយក្នុងការចិញ្ចឹមជីវិត ការរក្សារាងកាយ និងការរក្សាចិត្តឱ្យតាំងនៅ ដោយល្អ ព្រោះមនុស្សលោកទាំងអស់រមែងមាន វាសនា ឬគុណសម្បត្តិនិងកម្លាំងផ្សេងៗគ្នា ចំណែកខាងមនុស្សដែលខ្សត់ខ្សោយវាសនា និងគុណសម្បត្តិ ឬខ្សោយកម្លាំងកាយ និងសម្ងំនៅតាមទំនើងខ្លួនឯងមិនបាន ត្រូវធ្វើសមាគមគប់រកមនុស្សដែលសម្បូរវាសនា និងគុណសម្បត្តិ ឬកម្លាំង កាយ ឱ្យជួយណែនាំបង្ហាត់បង្រៀន ជួយជ្រោមជ្រែងដោយទ្រព្យរបស់ ឬភោជនាហារសម្រាប់ចិញ្ចឹមជីវិត។ មនុស្សដែលមាន វាសនា និងគុណសម្បត្តិខ្ពង់ខ្ពស់ ក៏ត្រូវតែទទួលអភិបាលរក្សាមនុស្សដែលនៅតូចទន់ខ្សី ឬ ថោកទាបជាងខ្លួន ដោយកិច្ច ប្រៀនប្រដៅ និងទ្រព្យសម្បត្តិជាដើមទុន ឬ អាហារសម្រាប់បរិភោគរាល់ថ្ងៃជាដរាប ដូចមាតាបិតាជាប្រធាននៃបុត្តធីតា។ ការឱ្យអាហារ ឬ គ្រឿងប្រើប្រាស់គ្រប់យ៉ាង នេះជាកល្យាណប្បវេណី ជាទំនៀមមួយដ៏វិសេស ជាប់មកតាំងពីមុនពុទ្ធកាល តាមបាលីលោកហៅថាទានៈ ប្រែថា ការឱ្យ។ បុគ្គលខ្លះក្នុងលោកនេះជាអ្នកមានចិត្តអាណិតទោរទន់ទៅរកមនុស្សសត្វដទៃ ហើយបានឱ្យគ្រឿងបរិភោគដោយសេចក្តីអាណិតតែម្យ៉ាងមិនអាស្រ័យយកកម្លាំងប្រើប្រាស់ ការឱ្យទានដូច្នេះហៅថា «ករុណាទាន»។ បុគ្គលខ្លះយល់ច្បាស់ក្នុងគុណូបការៈ ឬ គុណសម្បត្តិណាមួយរបស់លោកអ្នកមានគុណ មានមាតាបិតា គ្រូអាចារ្យ ឬ លោកអ្នកទ្រទ្រង់នូវគុណមាន សីលគុណជាដើម ក៏ធ្វើទានចំពោះលោកអ្នកមានគុណនោះ ការឱ្យទានដូច្នេះ ហៅថា «បូជាទាន ឬបដិការទាន»។ មនុស្សពួកខ្លះជាអ្នកមានចិត្តធូរទូលាយ ចង់ឱ្យប្រយោជន៍ ឱ្យសេចក្តីសុខ សេចក្តីចម្រើនដល់អ្នកដទៃ ដែលជាញាតិសាលោហិត ឬមិត្តសម្លាញ់ ឬក៏ជាមនុស្សរួមជាតិជាមួយគ្នា ដែលល្មមទទួលអំណោយការ សង្គ្រោះបាន ហើយចែកទ្រព្យសម្បត្តិជាដើមទុនក្តី គ្រឿងបរិភោគគ្រឿងប្រើ



www.elibraryofcambodia.org

ប្រាស់ក្តី ដើម្បីទំនុកបម្រុង ជួយជាកម្លាំង សង្គ្រោះឱ្យកើតប្រយោជន៍ស្មើមុខគ្នាឡើង ការឱ្យទានដូច្នេះហៅថា «អនុគ្គហទាន ឬ សង្គហទាន»។

នេះគ្រាន់តែសម្រង់ខ្លីមួយដែលយើងយកចេញពី «ទានកថា» របស់លោក ដែលសឱ្យឃើញថា លោកជាអ្នកឱ្យទាន និងជាអ្នកចូលចិត្តសង្គ្រោះចំពោះគ្នានឹងគ្នា ជាពិសេសចំពោះជនរួមជាតិខ្មែរនេះឯងតែម្តង។ នេះក៏គឺជាតម្លៃនៃគុណធម៌របស់លោកមួយផ្នែកយ៉ាងសំខាន់។

៙ C ៚



www.elibraryofcambodia.org

## ខណ្ឌទី ៦

### **ព្រះអាចារ្យ ហែម-ចៀវ និងការបដិវត្តន៍** :

ក្នុងពេលនោះ ដែលប្រទេសយើងនៅក្រោមអំណាចបារាំង មានអ្នកស្នេហាជាតិមួយចំនួន មានចិត្តមុះមុត ឥតខ្លាច គុកច្រវាក់ ឥតខ្លាចស្លាប់ ឥតខ្លាចចោលស្រុក បានលបបបួលគ្នាធ្វើការត ស៊ូប្រឆាំងនឹងបារាំង។ ក្នុងបណ្ដាវីរជនទាំងនោះមាន លោក **សឺង-ង៉ុកថាញ់** ជាមេដឹកនាំ បាន នាំគ្នាធ្វើបដិវត្តន៍ឡើង។ ការបដិវត្តន៍នេះ ត្រូវស្រាយឡើងក្នុងឆ្នាំ ១៩៣៦ តាមផ្លូវសារព័ត៌មាន « **នគរវត្ត**» សារព័ត៌មាននេះ មានគោលបំណងសរសេរដាស់តឿនក្រើនរំលឹកប្រជាជនខ្មែរ ពេល នោះឱ្យមានសង្ឃឹម ឱ្យមានសេចក្ដីក្លាហាន រៀបរាប់ពន្យល់អំពីតម្លៃនៃឯករាជ្យប្រទេស ឱ្យចេះ តស៊ូ . . . ។

ប្រជាជនខ្មែរគ្រានោះកាលបើឃើញកាសែតនេះ ក៏ដូចជាមានស្មារតីភ្លឺថ្លាគ្រប់គ្នា ចេះ ស្រឡាញ់សិទ្ធិសេរីភាព ឯករាជ្យ ស្រុកទេសឡើង។ ពួកបដិវត្តន៍ គឺពួកអ្នកសារព័ត៌មាន « **នគរវត្ត**» ជំនាន់នោះ មានប្រជាប្រិយភាពណាស់ មានព្រះ សង្ឃ អ្នកស្រែចំការ កម្មករ មន្ត្រីរាជ ការស្រឡាញ់រាប់អានកាន់តែច្រើន។

ហេតុការណ៍ទាំងនោះ នាំឱ្យរាជការអាណាព្យាបាលមានការចាប់អារម្មណ៍ហើយក៏ចាប់ផ្ដើ មតាមដាន សកម្មភាព របស់ពួកនេះជាលំដាប់។

ចំណែកអត្ថបទដែលសរសេរប៉ះពាល់ខ្លាំងៗលើរាជការ ឬរិះគន់ថាល្អៗ រំលឹកខ្មែរឱ្យ ចេះស្រឡាញ់ជាតិ ក៏ត្រូវគេ ដកចេញមិនឱ្យផ្សាយ។ ដូច្នេះ ជួនកាលកាសែតចេញក្រដាសទទេ ត្រង់កន្លែងគេដកនោះ។ ការនេះមានជាញឹកញយ ណាស់។

ដោយយល់ឃើញថា គ្រាន់តែផ្សាយដំណឹងបណ្ដុះស្មារតីខ្មែរឱ្យចេះយល់រឿងជាតិតែតាម ផ្លូវសារព័ត៌មានប៉ុណ្ណោះ ពុំគ្រប់គ្រាន់ទេ ដោយបារាំងចេះតែដកអត្ថបទល្អៗចេញមិនឱ្យផ្សាយ នោះ ទើបលោក **សឺង - ង៉ុកថាញ់** ជុំនុំគិតជាថ្មី រកមធ្យោបាយមួយផ្សេងទៀតបន្ថែមលើផ្លូវសារ ព័ត៌មាននេះ គឺបំបែកឱ្យមានក្រុមដើរទាក់ទងផ្ទាល់នឹងប្រជារាស្ត្រ និងក្រុមទាហានជើងក្រហម ទាហានជើងខ្មៅ ព្រមទាំងឃោសនាប្រាក់កាសមកបន្តសកម្មភាពបដិវត្តន៍ផង។ ក្រុមនេះមាន លោក **សឺង-ង៉ុកថាញ់** ជាមេ និងមានលោក **ប៉ិណ្ឌចន្ទ-ម៉ុល** លោក **នួន-ឌួង** និងលោក **ជុំ-មុ្ខង** ។ល។ ជាសមាជិក។

គឺជំនាន់នោះឯងហើយ ដែលព្រះអាចារ្យ **ហែម-ចៀវ** ត្រូវបានមានឈ្មោះរាប់បញ្ចូលទៅ ក្នុងក្រុមនេះដែរ ដ្បិតការល្បីល្បាញរបស់លោកខាងផ្នែកទេសនា និងខាងបណ្ដុះគំនិតថ្មីនោះ នាំ



www.elibraryofcambodia.org

ឱ្យពួកបដិវត្តន៍នឹកឃើញលោកភ្លាម ហើយចូលទៅប្រាស្រ័យទាក់ទងលោកភ្លាម សុំឱ្យលោកជួយក្នុងផ្នែកឃោសនាអប់រំពន្យល់ប្រជាពលរដ្ឋនេះឯង។

សម័យនោះ ទាហានជើងក្រហម និងទាហានជើងខ្មៅ ចេះតែទាស់ទែងគ្នាដោយប្រកាន់បក្សពួក។

បារាំងជាមេទាហានក៏សូមឱ្យមានព្រះសង្ឃខ្មែរទៅទេសនាទូន្មានទាហានទាំងនោះ គ្រប់បន្ទាយក្នុងមួយខែម្តង ដើម្បីអប់រំឱ្យ មានសីលធម៌ និងកិរិយាមាយាទល្អឡើង។

ការចាត់ព្រះសង្ឃឱ្យទៅទេសនា ឬធ្វើសន្និសីទដើម្បីអប់រំទាហានតាមលទ្ធិព្រះពុទ្ធសាសនាជាភារៈលើ ពុទ្ធសាសនបណ្ឌិត្យ។ ជូនកាលមានចាត់ព្រះសង្ឃឱ្យទៅទេសនារហូតដល់មាត់ជ្រូក (Chaudoc)ជាដើម។

កាលណោះលោក **សឺង-ង៉ុកថាញ់** ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យ និងព្រះរាជបណ្ណាល័យដែលរួមអាគារជាមួយ គ្នា ជាជំនួសក្រមការ **ជុំ-ម៉ៅ** ដែលផ្លាស់ចេញ ក្រោមបង្គាប់នាងកញ្ញាជាតិបារាំងម្នាក់ឈ្មោះ **ការប៊ីឡេស** (Melle Karpelés)ដែលមានឋានៈជាអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យ និងជាអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យ (Secrétaire Générale de l'Institut Bouddhique el Conservater de la Bibliothéque Royale)

លោក **សឺង-ង៉ុកថាញ់** ទទួលភារៈជាអ្នកចាត់ព្រះសង្ឃឱ្យទៅទេសនាប្រដៅទាហាន ជួសនាងកញ្ញា **ការប៊ីឡេស** ។ ម្លោះហើយ ជាឱកាសល្អរបស់លោក លោកជ្រើសរើសតែព្រះសង្ឃណាដែលស្នេហាជាតិមុតមាំ និងបានវោហារក្បោះក្បាយក្នុងការពន្យល់បញ្ចុះបញ្ចូលទាហានដោយអាស្រ័យធម្មទេសនា។ ពេលនោះព្រះអាចារ្យ **ហែម-ចៀវ** ក៏ត្រូវបានលោក **សឺង-ង៉ុកថាញ់** ជ្រើសរើសឱ្យទៅបំពេញបេសកកម្មនេះ។

លោកអាចារ្យ **ហែម-ចៀវ** បានទេសនាពន្យល់ទាហានជើងក្រហម ទាហានជើងខ្មៅឱ្យឈប់ ឈ្លោះគ្នា។ រាល់ដងលោកបានបង្ហាញឱ្យដឹងថា : យើងទាំងអស់គ្នាសុទ្ធតែជាខ្មែរ មានសាច់ឈាមដូចគ្នា បីដូចកូនដែល កើតមកពីផ្ទៃម្តាយតែមួយ យើងមិនគួរទាស់ទែងខ្វែងគំនិតគ្នាទេ។ រួចលោកតែងតែឆ្លៀតទេសនាបញ្ជៀងរំលឹកឱ្យដឹងថា : ការទាស់ទែងខ្វែងគំនិតគ្នានេះមុខគួរឱ្យស្តាយណាស់ ព្រោះគ្មានប្រយោជន៍ អ្វីសោះដល់រូបយើង ត្បិតយើងនៅក្រោម អំណាចគេគ្រប់គ្នា ទាស់ទែងគ្នាទៅក៏មិនឃើញនរណាគ្រាន់បើជាងនរណាដែរ បីដូចជាមាន់ប្រជល់ តើបានប្រយោជន៍អ្វី ក្រៅពីបានទទួលការឈឺចាប់ឆ្លុះធ្លាយរោមសាប ឈាមជាបខ្លួននោះ? ឯការចំណេញគឺបានទៅលើមនុស្សដែលជាម្ចាស់ នោះទៅវិញទេ។



www.elibraryofcambodia.org

ហើយអំពីនេះ លោកប្រព្រឹត្តមករហូតដល់ឆ្នាំ១៩៤២។

ដោយការទេសនាបញ្ឆិតបញ្ឆៀងនេះ ទាហានខ្មែរទាំងឡាយ ក៏សឹងបានយល់ដោយច្រើន ហើយកាន់តែស្គាល់ព្រះ អាចារ្យ **ហែម-ចៀវ** កាន់តែច្រើនឡើង គេក៏បានភ្លឺថ្លាស្មារតីឡើង។ ជំនាន់នោះទាហានខ្មែរយើងសក្តិធំបំផុតត្រឹម **វរិន្ទបាល**(Adjudant)។

ឯចំណែកគិញ **បារាំង** តែងឃ្លាំសកម្មភាពក្រុមបដិវត្តន៍នោះ ក៏តែងកត់សំគាល់នូវការដែលលោកអាចារ្យ **ហែម-ចៀវ** ទេសនានោះជាប្រក្រតីដែរ វាដឹងថាលោកគ្រូនេះមានគំនិតបដិវត្តន៍ហើយ តែវាពុំទាន់ចាប់ផ្ទាក់បាន នៅឡើយ ចាំសង្កេតទៅទៀត។

សូមជម្រាបថា នៅឆ្នាំ ១៩៤០ អ្នកដឹកនាំបដិវត្តន៍ បានទាក់ទងនឹងកងទ័ព **ជប៉ុន** ដែលទើបនឹងចូលមកដល់។ លោក **សឺង-ង៉ុកថាញ់** បានទៅទាក់ទងយ៉ាងសម្ងាត់ជាមួយនឹងមេទ័ព **ជប៉ុន** តាមរយៈមេហាងឈ្មោះ **ដាយ-ណាង់គូស៊ី** ដែលតាំងនៅមុខផ្សារចាស់ នៅជ្រុងផ្លូវពីកេ(ឥឡូវឧកញ៉ា**ផ្លុង**) និងជ្រុងផ្លូវអូហ៊ីយេ(ឥឡូវផ្លូវ **ពោធិ៍ចោរ**) ដើម្បីសុំជាជំនួយកងទ័ពរបស់**ជប៉ុន** ឱ្យគេជួយអន្តរាគមន៍ផង ប្រសិនបើមានការផ្លោះធ្លោយ បែកការណ៍ដឹងដល់**បារាំង** **បារាំង**នឹងធ្វើបាបនោះ។ មេហាង**ដាយណាង់គូស៊ី**នោះគឺជាមេហាងរបស់ **ជប៉ុន** តាំងសម្រាប់ធ្វើចារកម្មស៊ើបការណ៍ចំនួនកងទ័ព **បារាំង** នៅស្រុកខ្មែរដែរ។ មេហាង **ដាយណាង់គូស៊ី** ព្រមព្រៀង ជួយយើង ដោយបញ្ជាក់ប្រាប់លោក **សឺង-ង៉ុកថាញ់** ថា បើផ្លោះធ្លោយដោយហេតុណាមួយ ត្រូវតែប្រញាប់ប្រញាល់ រត់ចូលទៅឯកងតម្រួតយោធា **ជប៉ុន** (គឺកន្លែងសង់ធនាគារជាតិសព្វថ្ងៃនេះ) គេការពាយើងមិនឱ្យ**បារាំង**ចាប់បាន។ លោក **សឺង-ង៉ុកថាញ់** ក៏ប្រាប់លោកអាចារ្យ **ហែម-ចៀវ** និងអស់លោកឯទៀតឱ្យដឹងគ្រប់គ្នា។

លោកគ្រូអាចារ្យ **ហែម-ចៀវ** តែកាលណាមានឱកាសនិមន្តចេញទៅខេត្តក្រៅ តាមការនិមន្តន៍របស់គេ ឬ ដោយមានការអ្វី លោកតែងតែឆ្លៀតនិយាយពន្យល់បំភ្លឺអ្នកស្រុកអ្នកស្រែឱ្យស្រឡាញ់ជាតិ ឱ្យអង់អាច ឱ្យស្រឡាញ់សេរីភាព ។ល។ ការពន្យល់បំភ្លឺរបស់លោក ធ្វើឱ្យប្រជាពលរដ្ឋមានការភ្ញាក់រលឹកកាន់តែខ្លាំងឡើង ហើយគេតែងនាំគ្នារៃអង្គាស ប្រាក់កាសដោយជ្រះថ្លាចូលជាកុសលចំពោះរូបលោក ដើម្បីលោកនឹងយកទៅចាត់ចែងជាប្រយោជន៍ក្នុងការបដិវត្តន៍ថែម ទៀតផង។

៙ C ៙



www.elibraryofcambodia.org

**ខន្ឌទី ៧**

**ការចាប់ផ្ដើមលោកគ្រូអាចារ្យ ហែម-ចៀវ** :

តាំងពីបានចូលខ្លួនជាអ្នកឃោសនា ដើម្បីរំដោះស្រុកទេសនេះមក លោកគ្រូអាចារ្យ **ហែម-ចៀវ** ត្រូវបានគិញបារាំងតាមដានយ៉ាង ស្វិតស្វាញដូចជាគេធ្វើឡើងជាមួយនឹងពួកនយោបាយឯទៀត មានលោក **សឺង-ង៉ុកថាញ់** ជាដើមនោះដែរ។ គិញបារាំងតែងរាយការណ៍ ប្រាប់ចៅហ្វាយនាយគេរាល់ពេលមានរឿងប្លែកៗ។ ភ្ញៀវដែល ចេញចូលទាក់ទងនឹង លោកគ្រូអាចារ្យ **ហែម-ចៀវ** ជាញឹកញយនោះគឺ លោក **សឺង- ង៉ុកថាញ់, ចៅ សែនកុសល ឈុំ, ស៊ឹមវ៉ា ប៉ាច-ឈឿន** លោកតេជៈ **តាន់-ម៉ៅ** និងទាហានជើងខ្មៅ ជើងក្រហមខ្លះ ទៀត។ ព្រះអាចារ្យ **ហែម-ចៀវ** លោកមានមានះសិកា និងក្លាហានណាស់សូម្បីមិត្តភក្តិ លោកប្រាប់លោកឲ្យប្រយ័ត្នគេ ធ្វើបាបយ៉ាងណាក៏ដោយ។ ការមួយទៀតដែលនាំឱ្យលោកមានរឿងកាន់តែច្រើន គឺលោកមិនខ្លាចនឹងនិមន្តទៅទេសនា នៅកន្លែងពុទ្ធបរិស័ទណាស្អប់លោកទេ ឱ្យតែគេនិមន្តទៅ។ លោកជាបណ្ឌិតផ្នែកគណៈមហានិកាយ ទេសន៍ល្បីល្បាញ តើគេអ្នកប្រកាន់បុរាណនោះធ្វើម្ដេចនឹងសប្បាយចិត្ត?

ដោយសារមានឈ្មោះល្បីល្បាញគ្រប់មជ្ឈដ្ឋានដូច្នេះហើយបានជា លោកគ្រូអាចារ្យ **ហែម-ចៀវ** ត្រូវបាន ក្លាយខ្លួនជាទីដៅនៃ ចុងព្រួញ របស់គិញបារាំងនិងពួកអ្នកស្អប់លោក។ គិញបារាំងជាពិសេសដែលគេត្រូវការយកឈ្មោះ យសសក្តិរបស់គេផង គេក៏ខំធ្វើការ ទាល់តែបានសម្រេច។ គេយករឿង ព្រះអាចារ្យ **ហែម-ចៀវ** ដែលគេស្ដាប់បាន ទាំងប៉ុន្មានទៅជម្រាបចៅហ្វាយនាយរបស់គេ។ ចាងហ្វាងគិញបារាំងកាលណោះឈ្មោះ **ប្រូហ្សឺតុង** (Brocheton) មួយឈ្មោះ **សមប្រេ** (Sambray) មួយ។ នៅក្នុងសេចក្ដីរាយការណ៍របស់គេនោះ គឺថាលោកគ្រូអាចារ្យ **ហែម-ចៀវ** ជាមេដឹកនាំទាហាន និងរាស្ត្រខ្មែរឲ្យបះបោរប្រឆាំងបារាំង។ គ្រានោះ គេក៏ចាត់ទាហានខ្មែរចំនួន ១៥ នាក់ឱ្យចាំ ចាប់ដោយស្ងាត់កុំឱ្យបែកការណ៍។

នៅ ថ្ងៃទី ១៧ កក្កដា ១៩៤២ ពេលព្រឹក នៅនាយកដ្ឋានរដ្ឋមន្ត្រី គេឃើញចាងហ្វាងគិញម្នាក់និងលេខាធិការខ្មែរ ពីរនាក់ទៀតកាន់សំណុំរឿងមួយដុំផង បានរាយការណ៍ជម្រាបលោក **អ៊ុង អ៊ី** នាយករដ្ឋមន្ត្រី ព្រមទាំងលោក**ឆា-សាន** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងធម្មការ និងមន្ត្រីឯទៀត។

ក្រោយដែលបានជំនុំគ្នាមក លោក **ឆា-សាន** បានបញ្ជាទៅ លោក **ជុំ-មួង** ដែលពេលនោះធ្វើជាលេខាធិការ ក្រោមបង្គាប់លោក ឱ្យទៅនិមន្តលោកគ្រូអាចារ្យ **ហែម-ចៀវ** មក។ លោក



www.elibraryofcambodia.org

**ជុំ-មួង** ក៏ទៅវត្តឧណ្ណាលោម ជួបនឹង លោកគ្រូអាចារ្យ **ហែម-ចៀវ** ហើយទូលនិមន្ត តាមលោករដ្ឋមន្ត្រីប្រើ។ ព្រះអាចារ្យ **ហែម-ចៀវ** នឹកប្លែកដែរ សួរទៅលោក **ជុំ-មួង** ថាតើលោករដ្ឋមន្ត្រីឲ្យនិមន្តទៅមានការអ្វី? លោក **ជុំ-មួង** ក៏ទូលតាមដំណើរដែលបានឃើញ បារាំងមកជំនុំ តែពុំបានដឹងជារឿងអ្វី។

ក្រោយដែលបានចូលទៅបំពេញកិច្ចការនៅរោងពុម្ពសារព័ត៌មាន« **នគរវត្ត** » រួច លោកគ្រូអាចារ្យ **ហែម-ចៀវ** និង លោក **ជុំ-មួង** ក៏ធ្វើដំណើរមក។ នៅតាមផ្លូវ ព្រះអាចារ្យ **ហែម-ចៀវ** មានពុទ្ធដីកានឹងលោក **ជុំ-មួង** ថា : ប្រហែលជាគេនិមន្តទៅនេះ ដើម្បីសួរព័ត៌មានសកម្មភាពរបស់យើងហើយ បើគេសួរយើងឆ្លើយប្រកែកថា តែមិនដឹងទៅ!! រួចលោកមានពុទ្ធដីកាទៀតថា : លោក **សឺង-ង៉ុកថាញ់** មានផ្ដាំនឹងអាត្មាថា បើបារាំងវាដឹងរឿង ត្រូវប្រញាប់រត់ចូលទៅឯមន្ទីរកងអាវុធហត្ថជប៉ុនទៅ ទើបរួចខ្លួន!

លោកអាចារ្យ **ហែម-ចៀវ** និងលោក **ជុំ-មួង** យល់ថាច្បាស់ជាបារាំងវាដឹងរឿងសម្ងាត់ខ្លះហើយ ពេលនេះ ប្រហែលជាវាពុំទាន់ ធ្វើអ្វីទេ វាគ្រាន់តែហៅទៅសួរទេ មើលទៅ . . .

លោកអាចារ្យ **ហែម-ចៀវ** និងលោក **ជុំ-មួង** ទៅដល់សាលសន្និសីទគណៈរដ្ឋមន្ត្រី។ លោកគ្រូអាចារ្យ **ហែម-ចៀវ** ចូលតែមួយអង្គ លោកទៅក្នុងកន្លែងប្រជុំ ក៏ជួបនឹងអស់លោកបារាំងនិងខ្មែរកំពុងរង់ចាំ។ លោកពុំទាន់ បានសាកសួរដូចម្ដេចផង ស្រាប់តែលោក **ធរា-សាន** និយាយមកថា : ខ្ញុំព្រះករុណាឱ្យគេនិមន្តមកនេះ គឺដើម្បីសុំផ្សឹក ព្រះតេជគុណតែម្ដង ព្រោះព្រះតេជគុណមានទោស ដោយបានបំបះ បំបោរទាហាននិងប្រជារាស្ត្រ ឱ្យប្រឆាំងនឹងរាជការអាណាព្យាបាល !

ហើយលោករដ្ឋមន្ត្រីនេះបង្គាប់ទៅបំរើឱ្យទិញខោអាវមួយសម្រាប់មក។

លោកអាចារ្យ **ហែម-ចៀវ** ស្រឡាំងកាំង ធ្មឹងបន្តិច ទើបសួរទៅថា :

« អាត្មាមានបានបំបះបំបោរគេពីកាលណា? មានភស្តុតាងត្រង់ណាដែលថាអាត្មាបំបះបំបោរនោះ?»

លោក **ធរា-សាន** តបថា :

« រាជការអាណាព្យាបាល បានតាមសកម្មភាពរបស់ព្រះតេជគុណយូរណាស់ហើយ គេឃើញព្រះតេជគុណប្រព្រឹត្ត នោះច្បាស់លាស់ ច្រើនកន្លែងណាស់ ឥឡូវនេះខ្ញុំព្រះករុណាមិនអាចនឹងទូលព្រះតេជគុណអ្វីទៀតទេ គឺសុំតែផ្សឹកព្រះ តេជគុណតែប៉ុណ្ណោះឲ្យទៅជាគ្រហស្ថ ដើម្បីរាជការនឹងស៊ើបសួរតាមច្បាប់តទៅទៀត!



www.elibraryofcambodia.org

ព្រះអាចារ្យ **ហែម-ចៀវ** បាត់ព្រះឱស្ឋត្រឹមណោះ លោកយល់ថា អំពើរបស់លោកទាំងប៉ុន្មាននោះមាន ប្រតិកម្មហើយតើ។ អំពើណាមានប្រតិកម្ម អំពើនោះមានតម្លៃខ្ពស់បំផុត ត្រូវតែពេញចិត្តនឹងទទួលផលរបស់អំពើនោះចុះ!

ពេលនោះ គេបង្ខំដោះស្បង់ចីពរលោកចេញ ហើយឲ្យលោកស្លៀកខោ ពាក់អាវដែលជាប្រដាប់បិទបាំងកាយរបស់ គ្រហស្ថសុទ្ធសាធ។ គ្រាន់តែក្លាយខ្លួនជាគ្រហស្ថសាមញ្ញភ្លាម តម្រួតក៏បាននាំលោកចេញពីកន្លែងនោះ ចុះទៅរកឡានដែល ចតចាំងក្រៅរួច បើកបរចេញរឹងទៅមួយរំពេច។ លោក **ជុំ-មួន** ឃើញដូច្នោះធ្លាក់ថ្លើមក្តុក ដឹងថាគេយក លោកអាចារ្យ **ហែម-ចៀវ** ទៅធ្វើទោសប្រាកដហើយ។ ចេញម៉ោងធ្វើការ លោក **ជុំ-មួន** ក៏រត់ទៅជម្រាប លោក **សឺង-ង៉ុកថាញ់** លោក **សឺង-ង៉ុកថាញ់** ក៏ប្រាប់ថា : ឱ្យប្រយ័ត្នខ្លួន រឿងយើងបែកការណ៍ហើយ បារាំងប្រាកដជាតាមចាប់យើងខ្លះទៀតហើយ ឱ្យឆាប់រត់ចូលទៅកន្លែងកងអាវុធហត្ថជប៉ុនជាប្រញាប់!

ព្រមគ្នានឹងពេលចាប់ លោកអាចារ្យ **ហែម-ចៀវ** នោះបារាំងបានទៅចាប់លោក **នួន-ឌួន** ទៀតនាំយកទៅ។

នៅឯកុដិរបស់លោកគ្រូអាចារ្យ **ហែម-ចៀវ** ឯណោះវិញ ក្រោយដែលគេនិមន្តលោកទៅផុតដើម្បីផ្សឹកនោះ ពួកគិញបារាំងយួន ខ្មែរក៏តាំងចូលឆែកឆេរកកូរកកាយអស់ពេលប្រហែលពីរម៉ោង ដើម្បីរកឯកសារដែលគេត្រូវការ។ ពេលនោះ គេឃើញពួកទាំងនោះ រើកកាយទស្សនាវដ្តីកាសែត សៀវភៅធម៌ និងក្រដាសស្នាមផ្សេងៗបាចសាច ពាសពេញនៅមុខកុដិ ហើយគេយកតែឯកសារសំខាន់ៗ និងរូបថតរបស់លោកគ្រូអាចារ្យ **ហែម-ចៀវ** ប៉ុណ្ណោះ។ សកម្មភាពឆែកឆេរយ៉ាងពិនិត្យពិច័យនេះ នាំឱ្យអ្នកឈរមើលសំគាល់ដឹងថា គេនឹងចាប់ដល់អ្នកដទៃទៀតដែលមានការទាក់ទងនឹងព្រះអាចារ្យ **ហែម-ចៀវ** ដែលគេបានឃើញក្នុងសំបុត្រស្នាមផ្សេងៗនោះតទៅទៀតពុំខាន។ ដូច្នេះអ្នក ដែលខ្លាចមានទោសឥតជម្រះសឹងរួញខ្លួនគ្រប់គ្នា ខ្លះគេចភៀសទៅភ្លាម ខ្លះទៀតដែលមានរូបថតព្រះអាចារ្យ **ហែម-ចៀវ** នោះ ពុំហ៊ានទុករូបថតនោះទេ គេប្រមូលដុតចោលគ្មានសល់ សូម្បីស្រឡាញ់រាប់អានយ៉ាងណាក៏ដោយ ដ្បិតខ្លាចបារាំងតាំង ស៊ើបអង្កេតសម្បើមណាស់។

សូមបន្ថែមថា : មុននឹងមានការចាប់លោកអាចារ្យ **ហែម-ចៀវ** នេះ សម្តេចព្រះសង្ឃរាជសព្វថ្ងៃ កាលណោះលោកបានសុបិនថា មានរន្ទះបាញ់ត្រូវចេតិយធំនៅវត្តឧណ្ណាលោមផង ហើយលោកជ្រាបថាប្រាកដជាមាន រឿងធំហើយ។



www.elibraryofcambodia.org

**ចំណុចទី៨**

## បាតុកម្មសុំដោះលែងលោកអាចារ្យហែម-ចៀវ និងលោកនួន-ឌួង

រឿង **បារាំង** ចាប់លោកអាចារ្យ **ហែម-ចៀវ** នេះ មានប្រតិកម្មផ្អើលរំជួលឡើង ក្នុងបណ្តាព្រះសង្ឃជានិស្សិតសាលាបាលីជាន់ខ្ពស់និងវត្តនានាដែលជាមិត្រភក្តិ និងជាសិស្សរបស់លោក។

ឯក្រុមអ្នកបដិវត្តន៍ក៏ប្រញាប់ចាត់ការផ្សាយដំណឹងនេះថែមទៀត ទៅគ្រប់វត្តជិតឆ្ងាយតាមមធ្យោបាយដែលអាច ធ្វើបាន។ អ្នករត់ការស្ងិតស្ងាញកាលនោះមានលោក **ប៉ុណ្ណចន្ទ-ម៉ុល** ។ លោក **សឺង-ង៉ុកថាញ់** សម្រេចថា : ត្រូវតែធ្វើបាតុកម្មស្រុះគ្នាជាសន្តិវិធីមួយ ដើម្បីទាមទារសុំឱ្យ **បារាំង** ដោះលែងលោកអាចារ្យ **ហែម-ចៀវ** និងលោក **នួន-ឌួង** មកវិញ។ បាតុកម្មនោះត្រូវធ្វើនៅថ្ងៃទី ២០ កក្កដា ១៩៤២ វេលាព្រឹក ដោយចាត់ឱ្យព្រះសង្ឃឆាន់ពេលព្រឹកឱ្យហើយ។ ក្នុងបាតុកម្មនោះ ឥតត្រូវឱ្យមានអាវុធដំបងព្រនង់អ្វីទាំងអស់ គឺឱ្យដង្ហែចេញទៅសុំពី **បារាំង** ដោយសន្តិភាព បើ **បារាំង** ធ្វើបាប ឱ្យទាំងអស់គ្នាខំអត់សង្កត់ចិត្ត កុំប្រឆាំងវាយតប់វិញឱ្យសោះ ការយ៉ាងណាទៀតមាន **ជប៉ុន** ជាអ្នក ចាំជួយធ្វើអន្តរាគមន៍ហើយ ។ លោក **ប៉ុណ្ណចន្ទ-ម៉ុល** ក៏នាំចំណាត់នេះមកប្រាប់គ្នីគ្នា ជាពិសេសប្រាប់លោក **ប៉ាច-ឈឿន** ។

លុះដល់ថ្ងៃកំណត់ពេលព្រឹកនោះ ព្រះសង្ឃបានចេញពីគ្រប់វត្តជិតឆ្ងាយ មកជុំនៅវត្ត **លង្កា** មួយកន្លែង វត្ត **ឧណ្ណាលោម** មួយកន្លែង ទើបចេញដំណើរជាក្បួនដើរតម្រង់ទៅកាន់ទី **រ៉េស៊ីដង់** នៅខាងលិចវត្ត **ភ្នំ** ដោយរបៀប រៀបរយ។ នៅខាងមុខក្បួនមានបដាសរសេរថា : «សុំឱ្យដោះលែងលោកអាចារ្យ **ហែម-ចៀវ** និងលោក **នួន-ឌួង** មកវិញ» និង « ជយោ ព្រះពុទ្ធសាសនា! » ជាដើម។ លោក **ប៉ាច-ឈឿន** ជាអ្នកនាំមុខ។ ទៅដល់ទី **រ៉េស៊ីដង់** **បារាំង** មិនព្រមបើកឱ្យចូលទៅពិគ្រោះការឡើយ ក៏កើតទៅជារុញច្រានគ្នាទៅវិញទៅមក បាតុកររុញប៉ូលីស **បារាំង** ទៅមុខ ពួកនោះរុញឱ្យថយមកវិញ។ ឯលោក **ប៉ាច-ឈឿន** ដែលចូលខកទៅក្នុងទីនោះក៏ត្រូវពួកតិញបារាំងចាប់ អូសចូលទៅបាត់។ ការនោះនាំឱ្យបាតុករឯក្រៅកើតជ្រួលច្របល់ស្រែកថា : « វាចាប់គ្នាយើងម្នាក់ទៀតហើយ វាមិនចរចា នឹងយើងទេ ត្រូវចូលទៅជួយរំដោះគ្នាយើងមកវិញ! ទើបរុញជម្រុលទៅយកតែខ្លាំងមែនទែន ធ្លាយរបាំងមួយផ្នែក ពួកបារាំងអត់ពុំបានក៏តាំងច្រានមកវិញដោយប្រើដំបងមកលើបាតុករតែម្តង។ ពួកបាតុករមានការឈឺចាប់ ក៏សន្ធាប់ទៅវិញ ដោយវាយពួកនោះនឹងកូនតឹង ព្រះសង្ឃខ្លះក៏បុកនឹងចុងឆ័ត្រត្រូវក្បាលបារាំងបែកឈាមរហាមមួយរំពេច។ បាតុកម្មនេះ ក្លាយដោយស្វ័យប្រវត្តិជាអធិករណ៍ប្រកាប់ប្រចាក់គ្នាដោយកម្លាំងពេញបន្ទុក ពួកបារាំងនៅខាងក្នុងក៏ប្រញាប់និយាយទូរស័ព្ទ ហៅគ្នាគេបន្ថែមជំនួយ។ រំពេចនោះតម្រួតអាវុធគ្រប់



www.elibraryofcambodia.org

ដៃចំនួនពីរឡានមកដល់ភ្លាម។ ពួកបាតុករឃើញថាតស៊ូមិនឈ្នះក៏តាំងដោះដៃរត់ចេញ ពួកប្រដាប់អាវុធបំបែកហ្វូងបាតុករបាន តាំងដេញចាប់បាតុករព្រាតព្រោង ព្រះសង្ឃក៏តាំងបែកខ្ញែកខ្លះចោលឆ័ត្រ ខ្លះចោលស្បង់ គេចតែអាត្មាខ្លាចបារាំងចាប់។ បាតុកម្មថ្ងៃនោះត្រូវកងកម្លាំងរំលាយទៅ ឯពួកតម្រួត យោធាជប៉ុនក៏មិនហ៊ានជួយអ្វីដែរ ព្រោះខុសគម្រោងការដែលថាឱ្យធ្វើបាតុកម្មដោយសន្តិភាព នោះអស់ទៅហើយ។ អ្នករួម បាតុកម្មមេៗ គេត្រូវបារាំងចាប់តទៅទៀត ខ្លះរត់រួចទៅនៅឯវត្ត ស្រែចំការ ខ្លះរបូតទៅស្រុកសៀម ខ្លះត្រូវបារាំងចាប់បានក្នុងកាលក្រោយមក ដូចជាលោក **ម៉ុណ្ណចន្ទ-ម៉ុល** ព្រះភិក្ខុ **ប៉ាង-ខាត់** ជាដើម។

ការរំដើបរំជួលនេះ នាំឱ្យរដ្ឋបាលអាណាព្យាបាល បិទសាលាបាលីជាន់ខ្ពស់ នៅថ្ងៃទី១៨ សីហា ១៩៤២ទៅ។ ហើយបើកឡើងវិញនៅថ្ងៃទី ១ ធ្នូ ១៩៤២ បន្ទាប់ពីបានចាត់ការឱ្យ លោកសង្ឃមានរបៀបរៀបរយហើយនោះ។

ꩡ C ꩡ



www.elibraryofcambodia.org

**ខណ្ឌទី៩**

**ម្ដុកនោសនយោបាយ និងគុក** :

លោកអាចារ្យ **ហែម-ចៀវ** និង **នួន-ឌួង** នោះត្រូវពួកគិញបារាំងយកទៅសាកសួរនៅប៉ុយរ៉ូតិញឱ្យថតរូប និងផ្ដិតដៃទុក។ ក្រោយមកទៀតមានរូបលោក **ប៉ាច-ឈឿន** ម្នាក់ទៀតដែលទើបនឹងចាប់បានក្រោយ។

ក្រោយដែលបានសាកសួរហើយ គេបញ្ជូនទៅនៅគុកធំទាំងអស់គ្នា។

នៅក្នុងគុកធំមានទុក្ខវេទនាណាស់ រកពាក្យថ្លែងពុំបាន គេដាក់ខ្នោះដេកផ្ទាល់នឹងឥដ្ឋក្នុងបន្ទប់ងងឹតឈឹង ពេលបាយ ទឹក អាហារទាំងអស់សុទ្ធសឹងផ្អូម ចានដាក់បាយនោះគឺជាចំណូកដែលគេធ្លាប់ចូកលាមកនៅតាមចង្ក្របង្គន់ គេយកចាន របៀបនេះមកដាក់បាយឱ្យបរិភោគ។ លោកអាចារ្យ **ហែម-ចៀវ** លោកពុំទទួលទានល្ងាចទេ ដោយប្រកាន់ខ្លួនថា ជាសង្ឃដដែល។ នៅក្នុងគុកធំនោះ មានសេចក្ដីវេទនាស្មើឋាននរក។

រងទារុណកម្មនៅទីនោះប្រមាណជា ១០ ថ្ងៃ ទើបគេបញ្ចេញ ហើយគេដាក់ខ្នោះដៃនាំឡើងរថយន្តមួយចេញទៅ។ ទាំងបីនាក់នេះ មិនដឹងជាគេនាំទៅណាទៀតទេ ស្រាប់តែរថយន្តនោះឈប់នៅកំពង់ផែកប៉ាល់ក្រុមទ័រពីយ័រ នៅមុខផ្ទះលោក **រ៉េស៊ីដង់ស៊ុយប៉េរីយើរ** (ដែលឥឡូវនេះជាវិមាននៃរដ្ឋាភិបាល)។ ដល់មកត្រង់នេះទើបរាល់គ្នាភ្ញាក់ព្រើត ដឹងថាគេ បញ្ជូនទៅព្រៃនគរហើយ។ គេឱ្យចុះពីលើរថយន្ត ហើយបណ្ដើរចុះកប៉ាល់ គេឱ្យចុះទៅក្នុងឃ្លប់កប៉ាល់ដែលងងឹតឈឹងលែងដឹងទិសតំបន់អ្វីទាំងអស់ ឯដៃនិងជើងគេដាក់ខ្នោះដដែល។ អ្នកដែលបារាំងចាប់ទាំងប៉ុន្មានក្នុងរឿងជាមួយគ្នានេះ ដែលជាប់ឃុំនៅទីទៃពីគ្នា ស្រាប់តែបានជួបគ្នានៅក្នុងកប៉ាល់តែម្ដង។

មិនដឹងជាប៉ុន្មានម៉ោងទេ។ កប៉ាល់បើកចេញទៅនោះ ទាំងអស់គ្នាដូចជានៅក្នុងអន្លង់យប់ជ្រៅងងឹតរកពន្លឺគ្មាន។ លុះគ្រាតែកប៉ាល់ឈប់តែម្ដង ទើបគេដឹងថាដល់ដំណាក់ហើយ។ បន្ទាប់ពីកប៉ាល់ឈប់មក ពួក**ម៉ាត់ឡូ** ក៏មកបើកឃ្លប់ មានពន្លឺចូល គេនាំគ្នាបញ្ចេញទាំងអស់គ្នាឱ្យឡើងមកលើ រួចបញ្ជូនតាមឡានទៅទៀត ទៅឈប់នឹងអាគារធំជម្រឹងមួយ មានផ្លាកសរសេរជាអក្សរបារាំងធំៗថា «Prison Centrale» ទើបរាល់គ្នាដឹងថា នេះគឺជាគុកធំនៅព្រៃនគរហើយ។

រំពេចនោះ គេបណ្ដើរចូលទៅក្នុងគុកនោះភ្លាម គេឱ្យផ្លាស់សំលៀកបំពាក់ចាស់ចេញ ឱ្យស្លៀកពាក់ខោអាវ ខាងគុកគេវិញ រួចនាំចូលទៅក្នុងសាលធំ នៅជាន់ទី ៤ សាលលេខ ៣ ។ គុកធំនេះមានអាគារតូចធំជាច្រើន ខ្លះមួយជាន់ ខ្លះពីរជាន់ អាគារដែលធំហើយវែងជាងគេមានពីរ



www.elibraryofcambodia.org

សង់ជាប្អូនជាន់។ អាគារទាំងអស់ផ្នែកទី១ នៃសាលធំ គេឱ្យអ្នកទោស ខ្មែរនៅ ឯផ្នែកទី២ សម្រាប់អ្នកទោសយួន។ លោកអាចារ្យ **ហែម-ចៀវ** លោក **នួន-ឌួច** លោក **ប៉ាច-ឈឿន** សឹងតែហេវហត់ល្វើយណាស់ទៅហើយនោះត្រូវបញ្ចូលទៅខាងខ្មែរ។ ពេលដែលចូលទៅនោះ បារាំងជាអ្នកនាំបានទៅនិយាយនឹងខ្មែរម្នាក់ដែលមានរាងមាំក្រអាញ វាល់គ្នាយល់ថាប្រហែលជា **កាប៉ូរ៉ាល់** គុកនៅទីនោះ នៅក្បែរអ្នកនោះ ឯង មានអ្នកទោសមាឌមាំ ៤-៥ នាក់ទៀតអមៗ ក្នុងពេលអ្នកទាំងបីនាក់កំពុងឈរពិនិត្យទៅគេនោះ ស្រាប់តែមានអ្នកទោសផ្សេងម្នាក់ដើរសសៀរៗ មកជិតលោកអាចារ្យ **ហែម-ចៀវ** ហើយខ្សឹបតិចៗថា : « នែ ខ្ញុំអាណិតអ្នកឯងណាស់ ខ្ញុំសុំប្រាប់អ្នកឯងឱ្យដឹងខ្លួនមុន កុំឱ្យគេធ្វើបាបទាន់។ ខ្ញុំសុំប្រាប់ថា អ្នកដែលបារាំងកំពុងនិយាយរកនោះ គឺជាកាប៉ូរ៉ាល់ ត្រួតត្រាអ្នកទោសខ្មែរ, គាត់កាចសាហាវណាស់, គេហៅគាត់ថា ដៃបិរ តាមពាក្យយួន។ កាប៉ូរ៉ាល់នោះជាខ្មែរកម្ពុជាក្រោម ជា ទាហានជាប់ទោសយូរហើយ។ ពួកអ្នកឯងចូលទៅ ត្រូវមានការគោរពសំពះគាត់នោះដូចស្ដេច ហើយត្រូវពោលពាក្យសុំ ជ្រកកោនគាត់ផង ទើបសុខខ្លួន បើមិនដូច្នោះទេ នឹងត្រូវគាត់ និងពួកគាត់វាយដំច្រំធាក់ឥតប្រណីឥឡូវហ្នឹង! និយាយប្រាប់ ដូច្នោះហើយ អ្នកទោសនោះគេចខ្លួនទៅ។ ឯព្រះអាចារ្យ **ហែម-ចៀវ** ក៏រហ័សកេះប្រាប់លោក**នួន-ឌួច** ជាសិស្សឱ្យ ចាំធ្វើតាមពាក្យគេប្រាប់។ ពេលនោះបារាំងថយទៅវិញ កាប៉ូរ៉ាល់គុកក៏ហៅមកអ្នកទោសថ្មីទាំងបីនាក់។ លោក **នួន-ឌួច** ចូលមុនគេ លុតជង្គង់វារទៅជិតលើកដៃសំពះ។ កាប៉ូរ៉ាល់នោះសួរដោយទឹកមុខកាចថា : អាឯងមានរឿងអី បានជា មកជាប់គុក ? លោក **នួន-ឌួច** ឆ្លើយថា : សូមទោសលោក គេចោទថាខ្ញុំបានបំបះបំបោរក្បត់បារាំង។ គ្រាន់តែឮ ថាក្បត់បារាំងដូច្នេះ កាប៉ូរ៉ាល់នោះស្រាប់តែស្រែកថា : យើ អាឯងក្បត់បារាំងផង ! ចាត់ការទៅកនយើង ! គ្រាន់តែឮ បញ្ជាដូច្នេះ អ្នកទោសអមអង្គគេទាំងប៉ុន្មាននោះស្ទុះមកទាំងកម្រោល វាយទាត់ធាក់លោក **នួន-ឌួច** ដួលត្រឡប់ត្រឡិន រមៀលធ្លាក់ពីថ្នាក់លើតាមជណ្ដើរមកក្រោម សន្លប់ឈឹង។ លោកអាចារ្យ **ហែម-ចៀវ** នឹកខ្លោចចិត្តអាណិតសិស្ស។ លុះដល់លោក លោកចូលទៅសំពះនិយាយហួរហែថា : សូមទោសលោកម្ចាស់ ខ្ញុំបាទនេះជាព្រះសង្ឃទេ គេផ្សឹកមក ព្រោះ ខ្ញុំទេសនាពន្យល់ប្រជាជនបងប្អូនខ្មែរឱ្យចេះដឹងផ្លូវល្អ តិញបារាំងស្អប់ខ្ញុំ ចោទខ្ញុំថាក្បត់បារាំងទៅ សូមលោកមេត្តាផង !

កាប៉ូរ៉ាល់នោះដូចជាភ្ញាក់ :

- ឱ អ្នកឯងជាលោកសង្ឃទេ?



www.elibraryofcambodia.org

- ខ្ញុំបាទជាលោកសង្ឃ, ឯម្នាក់ទៀតនោះជាសិស្សរបស់ខ្ញុំ ជាអាចារ្យបង្រៀន មានរឿងដូចខ្ញុំដែរ ! សូមលោកម្ចាស់ មេត្តាផង ទានប្រោស !

- អូ ពួកអ្នកឯងជាមនុស្សស្លូតត្រង់ទេ មិនមែនជាចោរអីទេ អើអញអត់ឱនឱ្យខ្លះ !

ទើបកាប៉ូរ៉ាល់នោះបង្គាប់ទៅអង្គរក្សទាំងប៉ុន្មានឱ្យជួយលើកលោក **ឌួន-ឌួច** មករិតច្រវាក់ឱ្យជើងខ្លួន។

លោកអាចារ្យ **ហែម-ចៀវ** និងលោក **ឌួន-ឌួច** ត្រូវគេដាក់ឱ្យនៅជាមួយគ្នា ឯលោក **ប៉ាច-ឈឿន** គេដាក់នៅកន្លែងផ្សេង។

កន្លងមកប្រហែល ១០ ថ្ងៃ ស្រាប់តែឃើញគេបញ្ជូលអ្នកទោសជាគ្នាលោកមកពីភ្នំពេញទៀត គឺមានលោក**ប៊ុណ្ណចន្ទ-ម៉ុល** និងព្រះភិក្ខុ**ប៉ាង-ខាត់** ជាដើម។ លោកអាចារ្យ**ហែម-ចៀវ** ក៏ប្រញាប់និយាយប្រាប់កាប៉ូរ៉ាល់នោះជាស្រេចថា : សុំលោកអាណិត កុំធ្វើបាបអ្នកមកដល់ថ្មីៗនេះឡើយ គេជាគ្នាខ្ញុំ មានរឿងរ៉ាវដូចខ្ញុំដែរ សុំអាណិតទៅ !

កាប៉ូរ៉ាល់នោះ ក៏ងក់ក្បាលថា : អើមិនអីទេ មិនវាយដំច្រំធាក់ទេ តែត្រូវធ្វើការជាទម្ងន់ដូចគេឯងធម្មតា !

អ្នកទោសដែលទៅក្រោយនេះ ក៏បានធូរខ្លួនបន្តិច ដោយសាលោកអាចារ្យជួយនិយាយសម្រួល ចំពោះកាប៉ូរ៉ាល់ ដ៏ឃោរឃៅនោះ។

លោកអាចារ្យ **ហែម-ចៀវ** ថ្វីត្បិតតែជាប់ឃុំឃាំង លោកឆ្លៀតប្រាប់អ្នកទោសគ្នីគ្នាថា ឱ្យខំអត់ធ្មត់ទៅ យើងជា អ្នកត្រួសត្រាយផ្លូវឱ្យគេដើរហើយ រមែងតែពើបប្រទះគ្រោះថ្នាក់ដូច្នេះឯង! លោកអាចារ្យ**ហែម-ចៀវ** លោកពិសាបាយតែពេលព្រឹកប៉ុណ្ណោះ បាយល្ងាចលោកទុកឱ្យលោកអ្នកទោសគ្រហស្ថ មានលោក **ប៊ុណ្ណ- ចន្ទ-ម៉ុល** ជាដើម។

꧁꧂



www.elibraryofcambodia.org

**ខណ្ឌទី១០ ថ្ងៃគេកាត់ទោស** :

អ្នកទោសសំខាន់ៗ ដែលត្រូវគេហៅទៅកាត់ទោសមុនគេនោះមានរូបលោកអាចារ្យ **ហែម-ចៀវ**, **ប៉ាច-ឈឿន**, **នួន-ឌួច**, **ប៊ុណ្ណចន្ទ-ម៉ុល** ។ បន្ទាប់ពីបានសាកសួរតាមខ ដែលគេចោទថា យើងក្បត់ អាណាព្យាបាលនោះហើយ គេបានទៅជំនុំគ្នាមួយសន្ទុះ ហើយចេញមកវិញ គេស្រែកប្រកាសទោសឱ្យទាំងអស់គ្នា ដឹង :

- ឈ្មោះ **ប៉ាច-ឈឿន** ! អ្នកឯងត្រូវទោសប្រហារជីវិតបង់ !
- ឈ្មោះ **ហែម-ចៀវ** ! អ្នកឯងត្រូវទោសប្រហារជីវិត !
- ឈ្មោះ **នួន-ឌួច** ! អ្នកឯងត្រូវទោសប្រហារជីវិតបង់ !
-ឈ្មោះ **ប៊ុណ្ណចន្ទ-ម៉ុល** អ្នកឯងត្រូវទោសគុក ៥ ឆ្នាំ និងនីរទេស ១៥ ឆ្នាំមិនឱ្យចូលស្រុក ហើយត្រូវរឹបអូស យកទ្រព្យសម្បត្តិទាំងអស់ !

ក្រោយនោះ គេបញ្ជូនទៅគុកធំវិញ។ នៅនឹងគុកធំនោះអស់ពេលជាងពីរខែ ទើបគេបញ្ជូនអ្នកទោសខ្លះទៅកោះ ត្រឡាច។ ឯលោកទាំងបីនោះ ត្រូវរង់ចាំស្តាប់សេចក្តីសម្រេចសម្រាលទោស របស់លោកសេនាប្រមុខ **ម៉េតាំង** ប្រមុខរដ្ឋនៃប្រទេសបារាំងជាចុងក្រោយ។ ការរង់ចាំនេះត្រូវរងកម្មយ៉ាងទារុណ នៅគុកព្រៃនគរអស់ពេលយ៉ាងយូរក្រៃលែង។ ប្រហែល ៦-៧ ខែក្រោយមក ទើបគេប្រាប់ថា : លោកសេនាប្រមុខ **ម៉េតាំង** សម្រាលទោសពីប្រហារជីវិត មកត្រឹមទោសអស់មួយជីវិតវិញ។

ក្នុងខែមិថុនា ១៩៤៣ គេបញ្ជូនអ្នកទាំងបីទៅកាន់កោះត្រឡាច។

៙ C ៚



www.elibraryofcambodia.org

## **ខណ្ឌទី១១**

### **ជីវិតវាលទុក្ខរបស់លោកគ្រូអាចារ្យ ហែម-ចៀវ** :

នៅគុកកោះត្រឡាច គេដាក់អ្នកទាំងបីនៅក្នុងគុកលេខ ៤ ជាកន្លែងទោសឧក្រិដ្ឋ អស់អាយុទាំងអស់គ្នា។ គុកនោះ គេឱ្យអ្នកទោសវេញខ្សែព្ចរ និងធ្វើរបស់ផ្សេងៗតាមតែបារាំងបង្គាប់។ នៅគុកទី៤ គេហាមតឹងរ៉ឹងណាស់ មិនឱ្យមនុស្ស ផ្សេងទៅសាកសួរសុខទុក្ខមនុស្សទោស ដែលនៅក្នុងនោះសោះឡើយ ប៉ុន្តែលោក **ប៉ុណ្ណចន្ទ-ម៉ុល** ដែលមក ជាប់ទោសមុន ហើយដែលបានមានវាសនាធ្វើជាកាប៉ូរ៉ាល់អ្នកទោសម្នាក់ដែរនោះ បានលបលាក់ផ្ញើរបស់របរតិចតួច ទៅឱ្យអ្នកទាំងបីដែរ។ ប៉ុន្តែសេចក្តីលំបាកទុក្ខវេទនាដោយខ្លួនជាអ្នកទោស រងទារុណកម្ម បូកនឹងធាតុខុសគ្នានៃធម្មជាតិ បានធ្វើឱ្យលោកអ្នកទោសទាំងបីនេះ មានរោគាពាធបៀតបៀនជារឿយៗ។ ហើយនៅទីបំផុត លោកអាចារ្យ **ហែម-ចៀវ** មានរោគមួលជាខ្លាំង ឯលោក **នួន-ឌួច** កើតរោគស្ពឹកជើងដៃ។ លោក **នួន-ឌួច** ដោយពេទ្យ ចេះតែចាក់ថ្នាំគ្មានប្រសិទ្ធភាពច្រើនម្ជុលពេក ក៏ទៅជាកើតបូសត្រង់ត្រគាក ហើមយ៉ាងធំ ពេទ្យក៏វះយកខ្ទុះចេញយ៉ាងវេទនា បំផុត។ ឯលោកអាចារ្យ **ហែម-ចៀវ** ឈឺដាបមែនទែន ដើបលែងរួច ចុករមួលស្លឹតស្លាំងអស់ គ្មានសង្ឃឹមឡើយ !

គ្រូពេទ្យនៅកោះត្រឡាច គ្មានថ្នាំអ្វីព្យាបាលអ្នកជំងឺទេ។ ហើយចំពោះជំងឺមួលនេះ ក៏មិនដឹងជារកថ្នាំអ្វីដាក់ផង ពេទ្យចេះតែយកទឹកសមុទ្ទ ឬទឹកកំបោរសមកឱ្យផឹកបញ្ចុះប៉ុណ្ណោះ។

ដោយឃើញថាអ្នកទាំងពីរដាបមែនទែន គេបញ្ជូនទៅដាក់នៅសាលពេទ្យ។

លោក **ប៉ុណ្ណចន្ទ-ម៉ុល** បានដឹង ក៏ស្កាត់មកមើលអ្នកទាំងពីរឃើញថាលោកអាចារ្យ **ហែម-ចៀវ** ដាបបំផុតមើលទៅមិនជារទេ ក៏និយាយជូលកម្មករពេទ្យនៅទីនោះថា បើអ្នកជំងឺនោះស្លាប់ សុំមេត្តាកប់ខ្មោចដោយឡែកផង កុំកប់លាយឡំជាមួយខ្មោចដទៃ។ រួចក៏ឱ្យប្រាក់ខ្លះទៅកម្មករពេទ្យនោះ។ នៅកោះត្រឡាច នោះមានពេលខ្លះមនុស្ស ស្លាប់ច្រើន គេយកទៅកប់ ៥-៦ នាក់ តែក្នុងរណ្តៅមួយក៏មាន។ លោក **ប៉ុណ្ណចន្ទ- ម៉ុល** យល់ថាលោកអាចារ្យ **ហែម-ចៀវ** អស់មានអ្វីនឹងជួយកែកើតហើយ បើស្លាប់ទៅគាត់នឹងត្រូវចំណាំកន្លែងផ្នូររបស់លោកអាចារ្យត ទៅទៀត ហេតុនោះទើបគាត់ជូលឱ្យគេចាំកប់ដោយឡែកនោះ។

ចំណែកលោកអាចារ្យ **ហែម-ចៀវ** ក្រោយនោះ រោគាពាធកម្រើខ្លាំងមែនទែន ចុកស្វាយមាត់អស់ហើយ លោកនទៀលទៅរកលោក **នួន-ឌួច** ជាសិស្ស លោក **នួន-ឌួច** ក៏ខំរំកិលមករកដែរ លើកក្បាលលោកអាចារ្យជាគ្រូដាក់លើភ្លៅ ហើយជួយរឹតច្របាច់ពោះឱ្យគ្រូដោយគោរព



www.elibraryofcambodia.org

ឯទឹកភ្នែកក៏រអិលចុះទៅលើទ្រូងអាចារ្យជាគ្រូ លោកអាចារ្យ **ហែម-ចៀវ** ក៏មានទឹកភ្នែករលីងរលោងមកដែរដោយឈឺចាប់ពេក និងដោយអាណិតគ្នាទៅវិញទៅមកផុតថ្លែង។

ដោយដឹងខ្លួនឯងច្បាស់ថា អស់មានជីវិតតទៅទៀតហើយ លោកអាចារ្យ **ហែម-ចៀវ** បាននិយាយខ្សាវៗ ទៅកាន់លោក **ខ្លួន-ឌួច** ថា :

- **ខ្លួន-ឌួច** យើងវេទនាណាស់ ហើយអញមើលទៅមិនរស់ទេ មុខជាស្លាប់ពេលនេះហើយ ! **ឌួច** ឯងនៅឯក្រោយខំថែខ្លួនបន្តិចទៅ ក្រែងមានអាយុនឹងចាំមើលព្រឹត្តិការណ៍ស្រុកទេសតទៅទៀតផង !

លោក **ខ្លួន-ឌួច** និយាយទៅកាន់លោកអាចារ្យវិញថា :

- ព្រះតេជគុណ, ខ្ញុំអាណិតព្រះតេជគុណណាស់ ប៉ុន្តែមិនដឹងនឹងធ្វើម្តេច យើងទាំងពីរនាក់កំសត់ពេកណាស់ !

សូមជម្រាបថាលោក **ខ្លួន-ឌួច** ហៅលោកអាចារ្យ **ហែម-ចៀវ** ថា «ព្រះតេជគុណ» តាមទម្លាប់ខ្លួនជា សិស្សមកដរាប។

លោកអាចារ្យមានស្មារតីរឹងនៅតែនិយាយខ្សាវៗទាំងចុករមួលមកទៀត :

បានឯករាជ្យតែម្យ៉ាងប៉ុណ្ណោះ !

លោក **ខ្លួន-ឌួច** ឥតតបទៅវិញអ្វីទេ ចេះតែខំរិតឱ្យដោយថ្នាក់ថ្នម ទីបំផុតលោកគ្រូអាចារ្យក៏សម្លឹងមុខសិស្ស ដោយក្រសែភ្នែកថ្មិតថ្មង់ រួចលោកក៏រលត់ដង្ហើមទៅ ក្បាលលោកនៅកើយលើភ្លៅសិស្សដដែល។ លោក **ខ្លួន-ឌួច** ក៏ឱនក្បាលទ្រោបទៅលើទ្រូងគ្រូដោយគោរព ទឹកភ្នែកហូររហែងជាថ្មី ស្រដីតែម្នាក់ឯងថា : ឱ លោកគ្រូខ្ញុំ លោកលាចាក ចោលខ្ញុំទៅហើយ ! ជាសម្តីពោរពេញដោយសេចក្តីស្រណោះស្រមុតចិត្តឥតថ្លែងបាន។

ក្រោយមកពេទ្យក៏ចូលមកយកសពលោកអាចារ្យទៅ។ ពេលយកសពនេះ លោក**ខ្លួន-ឌួច** ហូរទឹកភ្នែកម្តងទៀត លោកតាមមើលឃើញគេយកសពព្រះអាចារ្យទៅដាក់លើកន្ទេលមួយស្អាត ហើយរុំនឹងក្រមាថ្មីមួយ រួចហើយមានខ្សែចង ត្រឹមត្រូវ។ លោក **ខ្លួន-ឌួច** តាមមើលទៀត ឃើញគេលើកសពដាក់លើរទេះកង់បី រុញយកទៅ . . . លោកមើលឃើញ តែត្រឹមណោះ ក៏ដាក់មុខចុះមកវិញ បិទភ្នែកមួយសន្ទុះផ្តាច់ខ្សែទឹកភ្នែកដែលធ្លាក់ចុះមក. . . លោកស្រមៃឃើញលោកអាចារ្យ **ហែម-ចៀវ** កាលនៅពីឆ្នាំមុនមិនទាន់មានរឿង ជាព្រះសង្ឃអង់អាច វាងវៃ ពូកែបង្រៀន ធ្វើឱ្យសិស្សរីករាយ សប្បាយ ពូកែទេសនាគេស្តាប់គ្រៀបគ្រា។ លោក **ខ្លួន-ឌួច** នឹកឃើញកាលគ្រូវ



www.elibraryofcambodia.org

បារាំងចាប់ចង ស្រមៃឃើញសេចក្តីទុក្ខ វេទនាយ៉ាងមហាសាហាវ្យនៅក្នុងគុក . . . ឥឡូវនេះ រូបដែលធ្លាប់មានសម្លេងមានឧត្តមគតិនេះ ត្រូវមករលាយសូន្យចាប់ពីពេលនេះហើយ !

លោក **ឡូន-ឌួច** សង្រេងអាណិតលោកគ្រូ អស់ពេលយ៉ាងយូរ ភ្លេចទាំងក្តីឈឺចាប់របស់ខ្លួនផង។

លុះក្រោយនោះ លោក **ប៉ុណ្ណចន្ទ-ម៉ុល** មកសួរ លោកក៏រាយរាប់តាមដំណើរដែលលោកអាចារ្យ **ហែម-ចៀវ** បានទទួលមរណភាពនោះ។ លោក **ប៉ុណ្ណចន្ទ-ម៉ុល** មានទឹកភ្នែកដែរ រួចថយទៅវិញ។ រំលងមក ជាយូរថ្ងៃ លោកក៏មកប្រាប់វិញថា : លោកបានឱ្យអ្នកទោសយកដុំថ្មធំៗទៅដាក់ចំណាំផ្នូរអាចារ្យហើយ ផ្នូរនោះមានលេខ ១.១១៣។ រួចលោក **ប៉ុណ្ណចន្ទ-ម៉ុល** ក៏ខំនិយាយលើកទឹកចិត្ត រំលឹកលោក **ឡូន-ឌួច** ថាឱ្យខំកាត់ចិត្តខ្លះទៅ កុំកើតទុក្ខពេក នាំឱ្យរោគចិត្តត្រួតថែមលើរោគកាយទៀត។ ជាកុសលដែរ លោក **ឡូន-ឌួច** បានគង់ជីវិតតមក។

៚ C ៚



www.elibraryofcambodia.org

**អវសាន**

លោកអាចារ្យ **ហែម-ចៀវ** បានទទួលមរណភាពក្នុងជន្មាយុ ៥៥ ឆ្នាំ នៅចុងឆ្នាំ ១៩៤៣ នៅលើកោះត្រឡាចដាច់ស្រយាល មានតែប្រវាលសាគរព័ទ្ធជុំវិញ តែស្រមោលឧត្តមគតិ និងគុណធម៌របស់លោក នៅតែរសាត់កាត់រលក មកចាំងផ្តិតលើដួងចិត្តខ្មែរគ្រប់គ្នាជានិច្ចពុំបានរលប់រលាយទៅតាមពេលវេលាសោះឡើយ។

ខ្មែរស្រុករនេះ និងស្រុករក្រោយ នៅតែចាំព្រះនាមលោក ចាំសកម្មភាពរបស់លោក ហើយរំលឹកគុណលោកជាប្រក្រតី។

អ្នករៀបរៀងសូមបញ្ជាក់ឱ្យច្បាស់ថា បានជាព្រះអាចារ្យ **ហែម-ចៀវ** ត្រូវយើងតំកល់តំកើង ព្រោះមកពីលោក ជាអ្នកនាំបំភ្លឺផ្លូវ ក្នុងការកសាងស្រុកខ្មែរឆ្ពោះទៅរកឯករាជ្យ ក្នុងសម័យដែលស្រុកនេះនៅក្រោមអំណាចបារាំងអាណានិគម និយមជិះជាន់ធ្វើបាបខ្មែរ។

ដោយហេតុតែបានសំគាល់ថាលោកអាចារ្យ **ហែម-ចៀវ** មានឧត្តមគតិស្នេហាជាតិ ហើយមានគុណធម៌ដ៏ ប្រសើរនោះ ទើបគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពលោកសេនាប្រមុខ**លន់-នល់** ប្រធានាធិបតីនៃសាធារណរដ្ឋខ្មែរ ក្នុងសម័យប្រជុំកាលពីថ្ងៃទី ២២ មីនា ១៩៧២ បានសម្រេចរឿងកិច្ចការលោកគ្រូអាចារ្យ **ហែម-ចៀវ** ក្នុងបណ្តាបញ្ហាដែលដាក់ប្រជុំថា :

« រដ្ឋាភិបាល បានទទួលស្គាល់នូវអំពើល្អទាំងឡាយដែលព្រះអាចារ្យ **ហែម-ចៀវ** បានធ្វើជូនប្រជាជាតិខ្មែរ ហើយបានសម្រេចថានឹងចាត់ចែងឱ្យបានផ្ទេរធាតុរបស់លោកពីកោះត្រឡាចមករដ្ឋធានីភ្នំពេញយើងវិញ»

ក្នុងរឿងនេះ រដ្ឋាភិបាលចាត់ប្រតិភូខ្មែរ ដែលមានរូបលោក **ម៉ុណ្ណចន្ទ-ម៉ុល** ជាអ្នកដឹកនាំឱ្យទៅកាន់ប្រទេសយួនខាងត្បូង ហួសទៅកោះត្រឡាចស្រាវជ្រាវរកព្រះអដ្ឋិធាតុព្រះសពអាចារ្យនេះមកប្រទេសខ្មែរវិញ ហើយធ្វើបុណ្យរំលឹក និងតម្កើងព្រះនាមព្រះសពដែលជា « អ្នកមេតំនិតម្នាក់ក្នុងបដិវត្តន៍ខ្មែរ ឆ្នាំ១៩៤២ » ដោយតម្កល់តម្កើងឋានៈលោកជា «**រដ្ឋបុរសជាតិ**» ក្នុងបច្ឆាមរណៈផង។

**៙ចប៛**



www.elibraryofcambodia.org

យើងខ្ញុំជាកូន ខ្ទៅ សំរ៉ង ខ្ទៅយ៉ាតណៃ ខ្ទៅ សុផល ខ្ទៅ វិសាល ខ្ទៅ រ៉ាមុន ខ្ទៅ ភារ៉ាដា ខ្ទៅ ចំរើន ខ្ទៅ ភារី បានឧបត្ថម្ភការផ្សាយសៀវភៅនេះជា ខ្មែរអ៊ីប៊ុក បង្កើតឡើងដោយ មូលនិធិខ្មែរសម្រាប់ការសិក្សា ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធ ឧបាសក ខ្ទៅ ពាញ នឹង ឧបាសិការ ឈរ យឿន
( ឃុំកំពង់ឃ្លាំង ស្រុកជីក្រែង ខេត្ត សៀមរាប )

# បានវាយបញ្ចូលកុំព្យូទ័រ ធ្វើជាអ៊ីប៊ុគ(eBook) ដោយនិស្សិតឈ្មោះ រ៉ុ-សិរីវិបុល ជានិស្សិតអក្សរសាស្ត្រខ្មែរ ឆ្នាំទី៤ ក្រុមA នៃ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ



www.elibraryofcambodia.org